៤៩-ទណ្ឌិតឈ្មោះ **ឡេង សុខឃាង** ភេទស្រី អាយុ ៥៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៨-០១-២០១៣ ពីបទ លួចលក់អចលនវត្ថុអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តែត្រូវអនុវត្តទោសក្នុងពន្ធនាគារចំនួន ១ ឆ្នាំ ៦ ខែ ឯទណ្ឌកម្ម ដែលនៅសល់ចំនួន ១ ឆ្នាំទៀតត្រូវព្យួរសាកល្បងក្នុងរយៈពេល ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៨៦ "ឆ" ទ ចុះថ្ងៃទី ០៤-៨-២០០៩ របស់សាលាឧទ្ធរណ៍ ។

៥០-ទណ្ឌិតឈ្មោះ **អ៊ិត សារ៉ាន់** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-៨-២០១២ ពីបទ រក្សាទុកដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ ក្រ៦ "ភ" ចុះថ្ងៃទី ២៦-៦-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥១-ទណ្ឌិតឈ្មោះ **នុត រ៉ាំមួ** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ..-១..-២០០៨ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "កបIV" ចុះថ្ងៃទី ២៧-៣-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ។

៥២-ទណ្ឌិតឈ្មោះ **ឌិត្យ ទាសនា** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២០-៨-២០០៨ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ "ក្រ.២" ចុះថ្ងៃទី ២៦-៣-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥៣-ទណ្ឌិតឈ្មោះ **សេខ តិរម្យ** ហៅ សុខ ណារិន ហៅ ហេង ចាន់ថា ភេទប្រុស អាយុ ៥០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-១២-២០១២ ពីបទ ឆបោក និងក្លែងបន្លំ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៣៣ "ង" ចុះថ្ងៃទី ១០-៤-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥៤-ទណ្ឌិតឈ្មោះ **ជួន បារាំង** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-១០-២០១២ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ "ណ" ចុះថ្ងៃទី ២៩-៣-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥៥-ទណ្ឌិតឈ្មោះ KANG MUN CHEOL ហៅ KANG RITHY ភេទប្រុស អាយុ ៥៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-៩-២០១១ ពីបទ ឆបោក និងរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តែទោសអនុវត្តនៅក្នុងពន្ធនាគារកំណត់ ៣ ឆ្នាំ ទោសសល់ពីនេះត្រូវព្យួរធម្មតាតាមអំណាចសាលដីកាលេខ ១៣ "ក្រIVអ" ចុះថ្ងៃទី ២៥-០១-២០១៣ របស់សាលាឧទ្ធរណ៍ ។

៥៦-ទណ្ឌិតឈ្មោះ **ពិន យៀន** ហៅ ហោយ ភេទប្រុស អាយុ ៦០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-១០-២០១២ ពីបទ ឆបោក ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តែទោសអនុវត្តពន្ធនាគារចំនួន ២ ឆ្នាំ និងទោសនៅសល់ព្យួរធម្មតា តាមអំណាចសាលដីកាលេខ ៧០ "ក្រVIញ" ចុះថ្ងៃទី ២២-១០-២០១៣ របស់សាលាឧទ្ធរណ៍ ។

៥៧-ទណ្ឌិតឈ្មោះ **ជាតិ សែ** ភេទប្រុស អាយុ ៦១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-០២-២០១០ ពីបទ ផ្តល់ទីតាំងសម្រួលដោយចេតនាឱ្យអ្នកដទៃប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៤៤ "ក្រII" ចុះថ្ងៃទី ២០-៤-២០១២ របស់សាលាឧទ្ធរណ៍ ។

៥៨-ទណ្ឌិតឈ្មោះ **ស្រ៊ុន ម៉ែន** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី [illegible]-៦-២០០៩ ពីបទ ទទួលផលចោរកម្ម ប៉ុនប៉ងមនុស្សឃាត និងប្រើប្រាស់អាវុធខុសច្បាប់ [illegible] ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៧៤ "ក្រVIញ" ចុះថ្ងៃទី ២២-១១-២០១៣ របស់សាលាឧទ្ធរណ៍ ។

៥៩-ទណ្ឌិតឈ្មោះ **ឡុង នីរិទ្ធ** ភេទប្រុស អាយុ ៤៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-៩-២០០៧ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៤៥ "ក" ចុះថ្ងៃទី ១១-៦-២០១០ របស់សាលាឧទ្ធរណ៍ ។

៦០-ទណ្ឌិតឈ្មោះ **ខៀង គាំង** ភេទប្រុស អាយុ ៤៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-១២-២០០៤ ពីបទ ជួញដូរមនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣០ "ច" ចុះថ្ងៃទី ២៩-៣-២០១០ របស់សាលាឧទ្ធរណ៍ ។

៦១-ទណ្ឌិតឈ្មោះ **ជា សុជាតិ** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-០១-២០០៥ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៥៣ "ក" ចុះថ្ងៃទី ០៦-៨-២០០៨ របស់សាលាឧទ្ធរណ៍ ។

៦២-ទណ្ឌិតឈ្មោះ **ទិន ហាំងម៉េង** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៨-២០០៤ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៦៤"ខ" ចុះថ្ងៃទី ១៧-៧-២០០៦ របស់សាលាឧទ្ធរណ៍ ។

៦៣-ទណ្ឌិតឈ្មោះ **ហ៊ឹម ស្រ៊ីន** ហៅ លាង ស្រ៊ីន ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-៧-២០០២ ពីបទ ប្លន់ទ្រព្យសម្បត្តិ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ ចុះថ្ងៃទី ២៧-០១-២០០៣ របស់សាលាដំបូងខេត្តក្រចេះ ។

៦៤-ទណ្ឌិតឈ្មោះ **វិចិត្រ រចនា** ហៅ ចាន់ណា ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-៨-២០១១ ពីបទ ជួញដូរគ្រឿងញៀនខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលដីកាលេខ ២០ "ក្រ.IVអ" ចុះថ្ងៃទី ២៥-០១-២០១៣ របស់សាលាឧទ្ធរណ៍ ។

៦៥-ទណ្ឌិតឈ្មោះ **ជាម ឆើង** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-៩-២០០៧ ពីបទ ធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦៣ "ក" ចុះថ្ងៃទី ៣០-៩-២០០៣ របស់សាលាដំបូងខេត្តកំពង់ចាម ។

៦៦-ទណ្ឌិតឈ្មោះ **មាស ម៉ានិត** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-១០-២០១២ ពីបទ ផ្តល់មធ្យោបាយលួចរត់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៩ "ខ" ចុះថ្ងៃទី ០៤-៧-២០១៣ របស់សាលាដំបូងខេត្តកំពង់ចាម ។

៦៧-ទណ្ឌិតឈ្មោះ **តែ ម៉ាន់ឈុំ** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-៧-២០០១ ពីបទ សម្លាប់មនុស្សដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣៨ ចុះថ្ងៃទី ២៦-៤-២០០៦ របស់តុលាការកំពូល ។

៦៨-ទណ្ឌិតឈ្មោះ **ម៉ាន សុភា** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-៨-២០០៨ ពីបទ ប៉ុនប៉ងធ្វើមនុស្សឃាតគិតទុកជាមុនក្នុងអំពើប្លន់ និងពីបទ ប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលដីកាលេខ ៧១ "ច" ចុះថ្ងៃទី ១៣-១១-២០០៩ របស់សាលាឧទ្ធរណ៍ ។

៦៩-ទណ្ឌិតឈ្មោះ **អ៊ុក អ៊ីន** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-០១-២០០៣ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ ចុះថ្ងៃទី ១៥-៧-២០០៣ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ។

៧០-ទណ្ឌិតឈ្មោះ **សេង សំណាង** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣-០២-១៩៩៧ ពីបទ ប៉ុនប៉ងសម្លាប់+សម្លាប់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥១ ចុះថ្ងៃទី ២៣-៩-១៩៩៧ របស់សាលាដំបូងខេត្តកំពត ។

**មាត្រា ៥** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៤១៤.៤៥៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០១៤

លេខៈ ៤៧៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៥៣៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម
ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា )

## តែងតាំង

លោកស្រី នី គឹមស្រ៊ាន

ជា

**ឧកញ៉ា**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៧វល.១៤០៥.៥៤៥

លេខៈ ៥៧៥ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៥៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ  នរោត្តម  សីហមុនី**
**សមានភូមិជាតិសាសនា  រក្ខតខត្តិយា  ខេមរដ្ឋរាស្ត្រ  ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា  សមូហោភាស  កម្ពុជឯករាជរដ្ឋបូរណសន្តិ  សុភមង្គលា  សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ  ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាធម្មពោធិសាល ជា  ស៊ីម**
ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

ទូវ

ក- គ្រឿងឥស្សរិយយស  **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់  **មហាសេរីវឌ្ឍន៍** :

១- វរសេនីយ៍ទោ **ហួត  ចាន់យ៉ារ៉ាន់**  
២- វរសេនីយ៍ទោ **ជា  លាងហៃ**  
៣- លោក **ខួន  រតនា**  
៤- លោក **ម៉ៅ  ស៊ីណា**  
៥- លោក **គង់  ទូនយូណែល**  
៦- លោក **ពុទ្ធ  លី**

ខ- គ្រឿងឥស្សរិយយស  **ព្រះមហាក្សត្រិយានី  ព្រះស៊ីសុវត្ថិមុនីវង្ស  កុសុមៈនារីរ័ត្ន**  ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- លោកជំទាវ **គីម  សត្យា**  
២- លោកស្រី **ចាន់  មុនី**

គ- គ្រឿងឥស្សរិយយស  **មុនីសារាភ័ណ្ឌ** ថ្នាក់  **មហាសេរីវឌ្ឍន៍** :

- លោក **ឈុន  វណ្ណារិទ្ធិ**

ឃ- គ្រឿងឥស្សរិយយស  **ព្រះរាជាណាចក្រកម្ពុជា**  ថ្នាក់  **មហាសេនា** :

១- លោកជំទាវ **មីន  កុសាន់ណា**  
២- វរសេនីយ៍ត្រី **សៀង  គីរុណា**  
៣- លោក **សំ  ណែត**  
៤- លោក **ម៉ែន  សារី**  
៥- លោក **អ៊ិត  សាន**  
៦- លោក **កែវ  សារ៉ាត់**

ង- គ្រឿងឥស្សរិយយស  **មុនីសារាភ័ណ្ឌ** ថ្នាក់  **មហាសេនា** :

- ឯកឧត្តម **ផាន់  សុភាព**

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- លោកវេជ្ជបណ្ឌិត **អួន  ទុំយ**  
២- អនុសេនីយ៍ឯក **ជួន  ឆា**  
៣- អនុសេនីយ៍ឯក **ញឹក  ស៊ីណាត**  
៦- លោក **គង់  ពិសិដ្ឋ**  
៧- លោក **ឃុន  បូរ**  
៨- លោក **ទិត  ដារិទ្ធ**

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

៤- អនុសេនីយទោ ហម គា
៥- លោក អ៊ិត ជំនិត
៩- លោក ឌី លាក់
១០- លោក យ៉ែម ហ៊ីម

ឆ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- អនុសេនីយ៍ឯក ចៅ កុសល
២- អនុសេនីយ៍ទោ តន់ វ៉ាទុធ
៣- អនុសេនីយ៍ត្រី គា ថន
៤- អនុសេនីយ៍ត្រី សាក់ ឃុនណា
៥- លោកស្រី ហួត សុខរី
៦- លោក ទ៉ុណា សីមឿន
៧- លោក លី ចាន់ដារិទ្ធ
៨- លោក ជៀម សេដា
៩- លោក លាច ស៊ុនលី
១០- លោក សេង សាវ៉ាន
១១- លោក ទីច ពគុណា
១២- លោក ទ៉ាន់ សារ៉ែត
១៣- លោក អ៊ុង សន
១៤- លោក ស៊ឹម ហាក់
១៥- លោក ស៊ុំ ឫទ្ធី
១៦- លោក សោម សុឃុន
១៧- លោក ពៅ វណ្ណា
១៨- លោក កែប សាន
១៩- លោក ជួន ទៀង
២០- លោក ដា វណ្ណា
២១- លោក ឆ្ងួច ចាន់ថន
២២- លោក ប៉ិច សុខឃឿន
២៣- លោក ចន្ទ ហៃ
២៤- លោក តៀក សុធី
២៥- លោក គង់ សុផាន់

ជ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- អនុសេនីយ៍ឯក ស៊ាន ទិត
២- លោក ជិន ឆ៊ច
៣- លោក កែច សីមា
៤- លោកស្រី ឈើន ចាន់ណា
៥- លោកស្រី សុខ សុផាវ៉ាត្ស
៦- លោក ម៉ាញ់ សារុន
៧- លោក ទ៉ាន់ ទ៉ុន
៨- លោក អេង ទិទ្ធ
៩- លោកស្រី អោក សុផល
១០- លោក ម៉ិញ អេង
១១- លោក នុត វណ្ណា
១២- លោក អ៊ុក សារឿន
១៣- លោក ឆាយ សាមុត
១៤- លោក ណី សម្បត្តិ
១៥- លោក អ៊ុំ ស៊ីផាត
១៦- លោក កូច សាម៉ន
១៧- លោក ហៀក សន
១៨- លោក ម៉ៃ ម៉ូយ
១៩- លោក ហួន ម៉េងហ៊ាង
២០- លោកស្រី ឆៀង ថូនី
២១- លោក អួច ស៊ឿន
១០៩- លោក លីច ជិនដា
១១០- លោក ប៊ុក សារុន
១១១- លោក ឈួន ផាន់ត
១១២- លោកស្រី អ៊ុក សុជាតិ
១១៣- លោកស្រី ស្តើង វណ្ណាថាវី
១១៤- លោក ហ៊ឹម គន្ធគីរ
១១៥- លោក មាស សម្បត្តិ
១១៦- លោកស្រី ពៅ សាម៉ោច
១១៧- លោក អ៊ុង គង់
១១៨- លោក ជិន សុគន្ធា
១១៩- លោក ជិន អេង
១២០- លោក សាន សើ
១២១- លោក ជិន ហុង
១២២- លោក ថាច់ ថាញ់
១២៣- លោកស្រី អេង ចាន់ថន
១២៤- លោក ឆាង សារុន
១២៥- លោក ម៉ក់ សាម៉ីឌី
១២៦- លោក សោ សាម៉ៃ
១២៧- លោក សំ ឆាត
១២៨- លោកស្រី ចាប យូ
១២៩- លោកស្រី ស៊ូ ហ៊ាន

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

២២- លោកស្រី សៅ សាទី
២៣- លោក ស៊ុំ សុខ
២៤- លោកស្រី សែម សម៉យ
២៥- លោក សុខ ម៉ៅ
២៦- លោក ហង់ សារ៉ែត
២៧- លោក ចក់ ម៉េត
២៨- លោក ដួង សុខា
២៩- លោកស្រី ម៉ៃ ចុំណ្ណះ
៣០- លោក សំ ប៊ុនតេង
៣១- លោក ហួង ទ្រៀង
៣២- លោកស្រី ឆាយ លីនណា
៣៣- លោក ឆេង ខុន
៣៤- លោកស្រី ឡៀច ហោរ
៣៥- លោក សុខ ឈើច
៣៦- លោក ជា ទុត
៣៧- លោក ប៊ុត សុខខេង
៣៨- លោកស្រី ជុំ សុជាតិលក្ខិណា
៣៩- លោក ទ្រាក់ សុខប៊ុនឡេង
៤០- លោក ឆៅ សុខហ៊ាង
៤១- លោកស្រី ពិន សាំប៉ូលី
៤២- លោក ហៀង ម៉េង
៤៣- លោក នួន លៀម
៤៤- លោក នូ ប៊ុនថន
៤៥- លោក ផុន សារ៉ន
៤៦- លោកស្រី ភន ណាទី
៤៧- លោក អេង ចាន់ធឿន
៤៨- លោក ហួន សុគន្ធ
៤៩- លោក សោ គឹមអ៊ាន
៥០- លោក នូ សុខណាលី
៥១- លោក អៀង សុខេង
៥២- លោក ជា យាង
៥៣- លោក ឃី ភព
៥៤- លោក សុន ស៊ិន
៥៥- លោក ម៉ៅ សំអុន
៥៦- លោក គឹម ផន
៥៧- លោក សេង លី
៥៨- លោក គួច ណាច
៥៩- លោក តាន់ តុងហៃ

១៣០- លោក ស៊ាង សុផា
១៣១- លោក ថេង ឈួន
១៣២- លោក ប៉ក់ អឿន
១៣៣- លោក សេក តឿន
១៣៤- លោក ពេជ្រ សីវុទ្ធ
១៣៥- លោក យឹម លឹម
១៣៦- លោក មា ឆាន់
១៣៧- លោក ហ៊ឹម ស្រស់
១៣៨- លោកស្រី នាង សារ៉ន
១៣៩- លោក គី ឡៅ
១៤០- លោក ឡូយ សារុន
១៤១- លោក គឹម សាន
១៤២- លោក ម៊ី សារ៉ាត
១៤៣- លោក ចន្ទ សៀង
១៤៤- លោក ឈួន សាធុជ
១៤៥- លោក សេង សុផល
១៤៦- លោក គង់ នាង
១៤៧- លោក ឈុប គា
១៤៨- លោក ឆយ គឹមឡេង
១៤៩- លោកស្រី ម៉េន ណារ៉ាត់
១៥០- លោកស្រី រ័ត្ន នាងសាពរ
១៥១- លោក សូ ជា
១៥២- លោក លឿម សូនី
១៥៣- លោក ញឿម សារឿន
១៥៤- លោក លឹម សិទ្ធា
១៥៥- លោក លន់ សំអឿន
១៥៦- លោក ស៊ិន សារ៉េត
១៥៧- លោក កែច លាត
១៥៨- លោក អោ អោក
១៥៩- លោក ជួប សន
១៦០- លោក គង់ សារុ
១៦១- លោកស្រី អ៊ួរ ដានី
១៦២- លោក លី ជួន
១៦៣- លោក អ៊ុច សយ
១៦៤- លោកស្រី ឡូន ណារី
១៦៥- លោក ហេង ម៉ូច
១៦៦- លោក ពៅ ប៊ុនថន
១៦៧- លោក យឹម ហៃ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៦០- លោក គឹម គីរី
៦១- លោក វុទ្ធ និត្យធារី
៦២- លោក ឆន ប៊ុន
៦៣- លោកស្រី មាស ផាត់ស្រមុទ្ធ
៦៤- លោក អ៊ា ណាំហៃ
៦៥- លោក គឹម សាបុល
៦៦- លោក ចាន់ សាទុត្ថ
៦៧- លោក សេង សុធា
៦៨- លោក ឃឹម ឫទ្ធី
៦៩- លោក សួង សាក់
៧០- លោក កៅ កែម
៧១- លោក នួច តំរុត
៧២- លោកស្រី ពុយ ស៊ុថារិទ្ធ
៧៣- លោក ភាំង កែវលក្ខណា
៧៤- លោក ញៀម ចន្ទី
៧៥- លោក រស់ ផាន់
៧៦- លោកស្រី ម៉ុំ គឹមនាង
៧៧- លោក ជា ភារណាល់
៧៨- លោក ស៊ូ សាន
៧៩- លោក ឡេង ស្រ៊ុង
៨០- លោកស្រី នួន សារ៉េត
៨១- លោក ឈួន វណ្ណា
៨២- លោក ថោង សុខុម
៨៣- លោក ប៉ែន ស្រ៊ឿង
៨៤- លោក គូ គឹមសេង
៨៥- លោក អៀម អ៊ុក
៨៦- លោក និត្យ សាម៉ឿន
៨៧- លោកស្រី ស្រី សុរិត
៨៨- លោក អ៊ុំ សារឿន
៨៩- លោក សួន ជឿន
៩០- លោក ស្តើង សុវណ្ណ
៩១- លោក ម៉ៅ រិទ្ធ
៩២- លោក សរ ម៉ែត
៩៣- លោក កែវ គួរ
៩៤- លោក ស៊ាន គ្រួយ
៩៥- លោក ប៉ែន សត្យា
៩៦- លោក ធួន សារិន
៩៧- លោក នាង ឆាយ

១៦៨- លោក ប៊ិច ឈាង
១៦៩- លោក ញ៉ឹក ឈឹន
១៧០- លោក ស៊ាំង សំបូរ
១៧១- លោក ថោង ទេពពិសិដ្ឋ
១៧២- លោក ធួន ឃួន
១៧៣- លោក ខៀវ សន
១៧៤- លោក លី ម៉ូល
១៧៥- លោក អ៊ាន់ ឈួម
១៧៦- លោក ឃុន ស្រ៊ុំ
១៧៧- លោកស្រី ម៉ុល សុខធីតា
១៧៨- លោក ស្វាយ ប៊ុន
១៧៩- លោក ស៊ូ តារុណ
១៨០- លោក ឈឹម នេត្រ
១៨១- លោកស្រី ស៊ិន សុភាព
១៨២- លោក គី គង់
១៨៣- លោក ឡុង សុភាព
១៨៤- លោក ម៉ុំ តឹក
១៨៥- លោកស្រី ម៉ែន សាមាន
១៨៦- លោក សំ លឹមហេង
១៨៧- លោក ថង សុត្ថា
១៨៨- លោក ផូ ស៊ាន
១៨៩- លោក ខែ ខន
១៩០- លោក ញ៉ុំ ប៊ុត
១៩១- លោក ឌិន សៀក
១៩២- លោក សៀន ស៊ឹម
១៩៣- លោក រស់ នឹន
១៩៤- លោក ទេព ចែម
១៩៥- លោក កែវ វន
១៩៦- លោកស្រី ឡេង សុតា
១៩៧- លោក ឈួរ ថៅ
១៩៨- លោកស្រី ញៀម សាអ៊ុន
១៩៩- លោក លន់ សម្បត្តិ
២០០- លោក និត សុធី
២០១- លោក ច្រឹក ឌឿន
២០២- លោក អ៊ួង សារ៉េន
២០៣- លោកស្រី ត្លួង គឹមលាង
២០៤- លោក វិញ ទ្រី
២០៥- លោក សុន អ៊ាន់ថា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៩៨- លោក ហែន កន
៩៩- លោក យស សន្ធា
១០០- លោកស្រី មាស ស៊ីចន្ថា
១០១- លោក ពូន យីន
១០២- លោក ស សាលីម
១០៣- លោក ប៉ុក ណារី
១០៤- លោក ខ្ញឹម សុផល
១០៥- លោក ស៊ុន សុភាព
១០៦- លោក រស់ អឿង
១០៧- លោក កែ ថុង
១០៨- លោកស្រី យា ធារិន
២០៦- លោក ហ៊ីង ពន្លក
២០៧- លោក អ៊ុក ម៉ាលីស
២០៨- លោក គុជ ប៊ុណ្ណារិទ្ធ
២០៩- លោក ឆាយ សុខុម
២១០- លោក មុំ សារឹម
២១១- លោក ចាន់ វណ្ណៈ
២១២- លោកស្រី ប៊ុន សុផាត
២១៣- លោក ហ៊ីង សារឿន
២១៤- លោកស្រី សៀង គីមពៅ
២១៥- លោក យូ ជាង

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៧ទស.១៤០៥.៥៤៨

លេខៈ ៥៧៦ ស.ណ
សំណៅ[illegible]ការចែកផ្សាយ
រាជធានីភ្នំពេញ [illegible] ១៦ ខែ [illegible] ឆ្នាំ២០១៤
[illegible]រាជរដ្ឋាភិបាល
សយ សុខា



# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៥៤៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ទ្រង់ប្រោសព្រះរាជទាន**

ដល់

គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា**

**Mr. Preet Bharara**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ការ.១៤០៥.៥៤៩

លេខ: ៥៥៨ ស.ណ
សំរាប់ចម្លងចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១៤
...រដ្ឋាភិបាល
ស៊ុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៥៤៤

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** កាត់ផ្ទៃដីទំហំ **៣០២.៤៦** ហិកតា ពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ដែលបានកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១២ ។

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣៧. ១៤០៥.៥៥០

លេខ: ៥៥៩ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៥៤៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់នាយទាហាន ថ្នាក់ **វរសេនីយ៍** នៃកងយោធពលខេមរភូមិន្ទ :

| | | | | |
|---|---|---|---|---|
| ១- វរសេនីយ៍ឯក | **ស្រី** | **សុធី** | អត្តលេខ | **១៧៩៥៨០** |
| ២- វរសេនីយ៍ឯក | **ម៉ុត** | **សំណាង** | អត្តលេខ | **២៣១៨៨៤** ។ |

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣៧. ១៤០៥. ៥៥១

លេខ: ៥៦០ ស.ណ

សំណៅ[illegible]មានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៤

[illegible]រាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៥៤៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ទ្រង់ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

១- លោក **ងួន គឹមសាន**

២- លោកស្រី **ខេង ស៊ីនាង**

៣- លោក **ឡេង យិន**

៤- លោក **ប៊ុន បាន**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការសបន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣៧. ១៤០៥. ៥៥៧

លេខ: ៥៥៥ ស.ណ
សំណៅដែលមាន[illegible]ជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០១៤
អគ្គលេខាធិការ[illegible]រដ្ឋាភិបាល

**ស៊ុយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៩៣ : អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលមាត្រា ៥ នៃអនុក្រឹត្យ លេខ១៥៨អនក្រ.បក**

**ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៤**

**ស្តីពីការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ**

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រាមួយ._**

មាត្រា៥ នៃអនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ ត្រូវបានកែសម្រួលដូចតទៅៈ

**មាត្រា ៥._ថ្មី**

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មមានរចនាសម្ព័ន្ធ ដូចតទៅៈ

១.នាយកដ្ឋានរដ្ឋបាលសរុប

២.នាយកដ្ឋានអត្រានុកូលដ្ឋាន

៣.នាយកដ្ឋានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
៤.នាយកដ្ឋានលិខិតឆ្លងដែន
៥.នាយកដ្ឋានសញ្ជាតិ
៦.នាយកដ្ឋានស្ថិតិប្រជាពលរដ្ឋ
៧.នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ។

**មាត្រា ៣.-** ពីរ

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ដើម្បីចុះហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រាបី
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចំណុះក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ស្តីពីអន្តោប្រវេសន៍

-បានឃើញព្រះរាជក្រមលេខនស/រកត/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ១៦អ.ន.ក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ១៥៧អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំណុះក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១៧៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ៥ នៃអនុក្រឹត្យ លេខ១៥៧អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំណុះក្រសួងមហាផ្ទៃ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពី តួនាទី ភារកិច្ច របៀបរបបធ្វើការងារនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងបណ្តានាយកដ្ឋានចំណុះ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅធានាដល់ការលើកកំពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងការងារអន្តោប្រវេសន៍ និងការងារជនភៀសខ្លួន សំដៅរក្សាសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

អនុក្រឹត្យនេះ ត្រូវដាក់អោយអនុវត្តចំពោះរាល់សកម្មភាពដឹកនាំនិងគ្រប់គ្រងជនបរទេសគ្រប់រូបដែលចូល-ចេញនិងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោមតាមច្បាប់និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## តួនាទី ភារកិច្ច របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍

**មាត្រា ៤.-**

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មានតួនាទីធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃ ដោយមានភារកិច្ចដូចតទៅ៖

-សិក្សា រៀបចំ កសាងពង្រឹងច្បាប់ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តិ គោលនយោបាយនិងផែនការយុទ្ធសាស្ត្រជាតិនិងវិធានការនានា សំដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងកិច្ចការអន្តោប្រវេសន៍ និងកិច្ចការជនភៀសខ្លួន

-ដឹកនាំគ្រប់គ្រងការធ្វើដំណើរឆ្លងកាត់ច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិទាំងអស់

-ដឹកនាំគ្រប់គ្រងការស្នាក់នៅ គ្រប់គ្រងស្ថិតិរបស់ជនបរទេសមិនមែនអន្តោប្រវេសន្ត ជនបរទេសអន្តោប្រវេសន្ត ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន ជនបរទេសសុំជ្រកកោន ជនភៀសខ្លួន និងជនជាតិខ្មែរធ្វើមាតុភូមិនិវត្តន៍តាមច្បាប់ជាតិ អន្តរជាតិជាធរមាន

-លើកគោលការណ៍ និងវិធានការបង្ការ ទប់ស្កាត់ ស្រាវជ្រាវ និងបង្ក្រាបបទល្មើសអន្តោប្រវេសន៍ បទល្មើសឧក្រិដ្ឋកម្មឆ្លងដែន បទល្មើសប៉ះពាល់ដល់សន្តិសុខជាតិ និងសុវត្ថិភាពសង្គមដែលបង្កឡើងដោយជនបរទេសនិងជនពាក់ព័ន្ធ

-គ្រប់គ្រងការងារទិដ្ឋាការចូលគ្រប់ប្រភេទដល់ជនបរទេសតាមច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិ។ការកំណត់លក្ខណៈសម្បត្តិដែលអាចផ្តល់ទិដ្ឋាការចេញ-ចូលមួយដង ឬច្រើនដង ឬដែលមិនអាចផ្តល់ទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-គ្រប់គ្រងការងារពន្យាទិដ្ឋាការបន្តការស្នាក់នៅរបស់ជនបរទេស ដែលកាន់លិខិតឆ្លងដែនធម្មតា។ ការកំណត់លក្ខណៈសម្បត្តិដែលអាចពន្យាទិដ្ឋាការ ឬមិនអាចពន្យាទិដ្ឋាការបន្តការស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-តាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានអន្តោប្រវេសន៍មានភារកិច្ចសហការជាមួយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន អនុវត្តការងារជនភៀសខ្លួនស្របតាមអនុសញ្ញាអន្តរជាតិឆ្នាំ១៩៥១ និងពិធីសារឆ្នាំ១៩៦៧ ទាក់ទិនទៅនឹងឋានៈនៃជនភៀសខ្លួន ដែលព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក

-តាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានអន្តោប្រវេសន៍មានភារកិច្ចសហការជាមួយក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈឬនិងអគ្គនាយកដ្ឋានពាក់ព័ន្ធ ដើម្បីគ្រប់គ្រងត្រួតពិនិត្យកម្មករនិយោជិតបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា និងកម្មករនិយោជិតខ្មែរដែលទៅធ្វើការងារក្រៅប្រទេស

-លើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេចក្នុងការបណ្តេញជនបរទេសដែលរំលោភច្បាប់ជាធរមានចេញពីព្រះរាជាណាចក្រកម្ពុជា

-កសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យអន្តោប្រវេសន៍តាមបច្ចេកវិទ្យា

-លើកយោបល់ជូនរដ្ឋមន្ត្រីពិនិត្យសម្រេចលើសំណើសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ និងសំណើសុំពន្យាសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍សំរាប់ជនបរទេសអន្តោប្រវេសន្តស្របច្បាប់ ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន និងជនបរទេសដែលទទួលឋានៈជាជនភៀសខ្លួនស្របច្បាប់

-ត្រួតពិនិត្យ និងផ្តល់លិខិតធ្វើដំណើរសំរាប់ជនបរទេសអន្តោប្រវេសន្តស្របច្បាប់ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន និងជនភៀសខ្លួន

-ដឹកនាំត្រួតពិនិត្យការផ្តល់ប័ណ្ណឆ្លងព្រំដែនដល់ប្រជាពលរដ្ឋខ្មែរដែលរស់នៅជាប់តំបន់ព្រំដែន និងផ្តល់លិខិតធ្វើដំណើរសំរាប់ពលរដ្ឋខ្មែរធ្វើមាតុភូមិនិវត្តន៍

-គ្រប់គ្រងទីកន្លែងត្រៀមបណ្តេញចេញចំពោះជនបរទេសធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គមរង់ចាំការបំពេញបែបបទបណ្តេញចេញ ឬបញ្ជូនទៅតុលាការតាមនីតិវិធីច្បាប់

-តាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រីមហាផ្ទៃ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ទំនាក់ទំនង និងសហការជាមួយអង្គការអន្តរជាតិ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ បណ្តាប្រទេសជាមិត្ត និងវិស័យឯកជននានា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ជំនួយបច្ចេកទេស ជំនួយឧបករណ៍ សំភារៈផ្សេងៗនិងការងារពាក់ព័ន្ធដទៃទៀត ដើម្បីសម្រួល និងគាំទ្រដល់ការងារជំនាញអន្តោប្រវេសន៍

-ត្រួតពិនិត្យ និងផ្តល់លិខិតបញ្ជាក់ប្រវត្តិទោស និងលិខិតបញ្ជាក់ការបាត់លិខិតឆ្លងដែន ឬឯកសារធ្វើដំណើរផ្សេងៗរបស់ជនបរទេសក្នុងរយៈពេលស្នាក់នៅ និងធ្វើការក្នុងព្រះរាជាណាចក្រកម្ពុជា

-គ្រប់គ្រងទិន្នន័យជនបរទេសដែលជាប់ពន្ធនាគារ និងជនបរទេសដែលជួបគ្រោះថ្នាក់ផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា

-បង្កើតគេហទំព័ររបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីផ្សព្វផ្សាយព័ត៌មាននិងទទួលឆ្លើយតបព័ត៌មានផ្សេងៗ

-សម្របសម្រួលនិងសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋាននានាចំណុះក្រសួងមហាផ្ទៃ ដើម្បីបំពេញភារកិច្ចតាមតួនាទីភារកិច្ចរបស់ខ្លួន

-ដឹកនាំគ្រប់គ្រងមន្ត្រីអន្តោប្រវេសន៍ទាំងនៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងមន្ត្រីបំរើការងារអន្តោប្រវេសន៍នៅថ្នាក់ក្រោមជាតិ អនុវត្តអោយបានត្រឹមត្រូវតាមច្បាប់ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្ត

-ស្នើតែងតាំង ឬផ្លាស់ប្តូរភារកិច្ច លើកសរសើរ និងការអនុវត្តវិន័យមន្ត្រីអន្តោប្រវេសន៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពិនិត្យសម្រេច

-រៀបចំផែនការបណ្តុះបណ្តាលកសាងធនធានមនុស្ស ដើម្បីពង្រឹងសមត្ថភាពជំនាញវិជ្ជាជីវៈ ភាសាបរទេសដល់មន្ត្រីអន្តោប្រវេសន៍

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍តាមរបបកំណត់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី ៣
## តួនាទី ភារកិច្ច បណ្តានាយកដ្ឋាន
## ចំណុះអគ្គនាយកដ្ឋានអន្តោប្រវេសន៍

**មាត្រា ៥.-**

នាយកដ្ឋានរដ្ឋបាលសរុប

នាយកដ្ឋានរដ្ឋបាលសរុប មានតួនាទីភារកិច្ចធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍លើៈ

-ការងាររដ្ឋបាលសរុប រួមមាន ការចាត់ចែងឯកសារនានា ការរៀបចំកិច្ចប្រជុំ សន្និបាត សិក្ខាសាលា រួមទាំងការធ្វើកំណត់ហេតុ ឬរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំ ការងារពិធីការ ការគ្រប់គ្រងត្រា ការងារបណ្ណសារ ទំនាក់ទំនងសាធារណៈ និងធ្វើរបាយការណ៍បូកសរុបទិសដៅការងារ

-ធ្វើការសម្របសម្រួលជាមួយបណ្តានាយកដ្ឋាន សមត្ថកិច្ចចំណុះអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្នុងការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងដល់ការងារអន្តោប្រវេសន៍

-ធ្វើកិច្ចសហការជាមួយបណ្តានាយកដ្ឋានពាក់ព័ន្ធ លើកផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ឬកម្មវិធីការងាររបស់អគ្គនាយកដ្ឋាន

-ទទួលពាក្យបណ្តឹងទាក់ទងនឹងវិវាទរបស់ជនបរទេស កម្មករនិយោជិតបរទេស ព្រមទាំងសហការជាមួយស្ថាប័នពាក់ព័ន្ធធ្វើការសម្របសម្រួល និងកសាងឯកសារជូនថ្នាក់ដឹកនាំ ពិនិត្យសម្រេច

-ធ្វើការងារគេស្តុការ គណនេយ្យ និងការងារបុគ្គលិកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍

-សហការជាមួយអគ្គនាយកដ្ឋានកស្តុការ និងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងការប្រមូលចំណូលថវិកាជាតិពីការងារអន្តោប្រវេសន៍តាមការកំណត់

-រៀបចំបែបបទ សំរាប់លិខិតបញ្ជាក់ប្រវត្តិទោស និងលិខិតបញ្ជាក់ការបាត់លិខិតឆ្លងដែន ឬឯកសារធ្វើដំណើរផ្សេងៗរបស់ជនបរទេសក្នុងរយៈពេលស្នាក់នៅ និងធ្វើការក្នុងព្រះរាជាណាចក្រកម្ពុជា

-បំពេញការងារសំរាប់ការសហការទំនាក់ទំនងអន្តរជាតិ ដោយអនុវត្តតាមផែនការកិច្ចព្រមព្រៀងរបស់ក្រសួងមហាផ្ទៃជុំវិញការងារអន្តោប្រវេសន៍

-គ្រប់គ្រងគេហទំព័ររបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានរដ្ឋបាលសរុបតាមរបបកំណត់ជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ប្រគល់ឲ្យ។

**មាត្រា ៦.-**

នាយកដ្ឋានជនបរទេសមិនមែនអន្តោប្រវេសន្ត និងបច្ចេកវិទ្យា

នាយកដ្ឋានជនបរទេសមិនមែនអន្តោប្រវេសន្ត និងបច្ចេកវិទ្យា មានតួនាទី ភារកិច្ចធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍លើ ៖

-កសាងផែនការសកម្មភាពការងារគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន្ត និងគ្រប់គ្រងប្រព័ន្ធទិន្នន័យអន្តោប្រវេសន៍

-ពិនិត្យផ្តល់ទិដ្ឋាការគ្រប់ប្រភេទនៅតាមបណ្តាច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិ និងពន្យាទិដ្ឋាការស្នាក់នៅលើលិខិតឆ្លងដែនធម្មតាសំរាប់ជនបរទេសមិនមែនអន្តោប្រវេសន្តតាមនីតិវិធីច្បាប់

-រៀបចំបែបបទផ្តល់ទិដ្ឋាការចេញសំរាប់ជនបរទេសដែលទទួលបានលិខិតឆ្លងដែនធម្មតាថ្មី ឬឯកសារធ្វើដំណើរមានតម្លៃស្មើដែលផ្តល់ដោយស្ថានទូត ឬស្ថានកុងស៊ុលបរទេស ក្នុងករណីលិខិតឆ្លងដែនខូចបាត់ អស់សុពលភាពឬដោយប្រការផ្សេងៗ

-កសាងកែសម្រួលបែបបទ និងលិខិតបទដ្ឋាននានា សំដៅបំរើសេវាផ្តល់ទិដ្ឋាការ និងការងារពន្យាការស្នាក់នៅនៃជនបរទេសមិនមែនអន្តោប្រវេសន្ត

-អនុវត្តការផាកពិន័យតាមគោលការណ៍កំណត់ ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលស្នាក់នៅហួសរយៈពេលកំណត់

-ពិនិត្យស្នើសុំការសម្រេចបដិសេធផ្តល់ទិដ្ឋាការចូលប្រទេស ក្នុងករណីល្មើសច្បាប់អន្តោប្រវេសន៍ឬច្បាប់ផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា និងធ្វើការបណ្តេញចេញនៅនឹងកន្លែង

-ពិនិត្យតាមដានស្រាវជ្រាវវិភាគវាយតម្លៃឯកសារធ្វើដំណើរគ្រប់ប្រភេទ និងព័ត៌មានអន្តោប្រវេសន៍ដែលទទួលបានពីប្រភពផ្សេងៗ

-គ្រប់គ្រងនិងផ្ទៀងផ្ទាត់ជាមួយអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុនូវចំនួនសន្លឹកទិដ្ឋាការស្អិតដែលបានប្រើប្រាស់

-កសាងលិខិតបទដ្ឋានច្បាប់សម្រាប់គ្រប់គ្រង ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាក្នុងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីត្រួតពិនិត្យប្រព័ន្ធទិន្នន័យអ្នកដំណើរចូល-ចេញ ប្រព័ន្ធទិន្នន័យមុខសញ្ញា និងប្រព័ន្ធទិន្នន័យផ្សេងៗទៀតពាក់ព័ន្ធនឹងការងារអន្តោប្រវេសន៍

-តាមដានក្តាប់ និងវិភាគព័ត៌មានដែលពាក់ព័ន្ធនូវសភាពការណ៍អន្តោប្រវេសន៍សកល ដើម្បីមានមូលដ្ឋានក្នុងការលើកគោលការណ៍ វិធានការបង្ការទប់ស្កាត់នូវហានិភ័យដែលអាចកើតឡើង

-ធ្វើការងារភស្តុភារ គណនេយ្យ និងការងារបុគ្គលិករបស់នាយកដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានជនបរទេសមិនមែនអន្តោប្រវេសន្ត និងបច្ចេកវិទ្យាតាមរបបកំណត់ជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ប្រគល់ឲ្យ។

**មាត្រា ៧.-**

នាយកដ្ឋានជនបរទេសអន្តោប្រវេសន្ត

នាយកដ្ឋានជនបរទេសអន្តោប្រវេសន្ត មានតួនាទី ភារកិច្ចធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍លើ ៖

-កសាងផែនការសកម្មភាពលើការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន្តស្របច្បាប់ និងមិនស្របច្បាប់

-រៀបចំបែបបទ នីតិវិធីសុំការសម្រេចទទួលស្គាល់ផ្តល់ប័ណ្ណស្នាក់នៅ ឯកសារធ្វើដំណើរ និងឯកសារផ្សេងៗទៀតដល់ជនបរទេសអន្តោប្រវេសន្តស្របច្បាប់

-ធ្វើបច្ចុប្បន្នភាពជាប្រចាំចំពោះជនបរទេសអន្តោប្រវេសន្ត និងមានវិធានការដោះស្រាយតាមនីតិវិធីច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា

-ពិនិត្យ ស្រាវជ្រាវ សម្ភាសន៍ កំណត់អត្តសញ្ញាណសញ្ជាតិខ្មែរចំពោះជនចំណាកស្រុកនិងជនដែលត្រូវធ្វើមាតុភូមិនិវត្តន៍ ព្រមទាំងធ្វើសមាហរណកម្មរបស់ជនមាតុភូមិនិវត្តន៍ បញ្ចូលទៅក្នុងសង្គមជាតិ

-តាមការប្រគល់សិទ្ធិពីអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គភាពពាក់ព័ន្ធ ដើម្បីគ្រប់គ្រងកម្មករនិយោជិតខ្មែរដែលទៅធ្វើការងារក្រៅប្រទេស

-លើកសំណើសុំគោលការណ៍ទុកជានិរាករណ៍ និងដកហូតរាល់ឯកសារលិខិតស្នាមនានា ព្រមទាំងបណ្តេញចេញចំពោះជនបរទេសអន្តោប្រវេសន្តដែលបំពានច្បាប់អន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា

-ធ្វើការងារភស្តុភារ គណនេយ្យ និងការងារបុគ្គលិករបស់នាយកដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានជនបរទេសអន្តោប្រវេសន្តតាមរបបកំណត់ជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ប្រគល់ឲ្យ។

**មាត្រា ៨.-**

**នាយកដ្ឋានជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន**

នាយកដ្ឋានជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន មានតួនាទីភារកិច្ចធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍លើៈ

-កសាងផែនការសកម្មភាពលើការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន

-រៀបចំបែបបទ និងដំណើរការនីតិវិធីសុំការសម្រេចទទួលស្គាល់ ផ្តល់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ឯកសារធ្វើដំណើរនិងឯកសារផ្សេងទៀតដល់ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន និងសមាជិកគ្រួសារផ្ទាល់

-រៀបចំសំណើរបស់អគ្គនាយកដ្ឋាន ដើម្បីសុំគោលការណ៍បញ្ឈប់ការទទួលស្គាល់ ការផ្តល់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ការផ្តល់ឯកសារធ្វើដំណើរ និងឯកសារផ្សេងៗទៀតរបស់ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យសម្រេច

-តាមការប្រគល់សិទ្ធិពីអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គភាពពាក់ព័ន្ធ ដើម្បីគ្រប់គ្រងធ្វើអធិការកិច្ចលើកម្មករនិយោជិតបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា និងកម្មករនិយោជិតខ្មែរដែលទៅធ្វើការងារក្រៅប្រទេស និងផាកពិន័យចំពោះកម្មករនិយោជិតបរទេសណាដែលបំពានច្បាប់ការងារ និងច្បាប់អន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា

-ធ្វើការងារភស្តុភារ គណនេយ្យ និងការងារបុគ្គលិករបស់នាយកដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន តាមរបបកំណត់ជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ប្រគល់ឲ្យ។

**មាត្រា ៩.-**

**នាយកដ្ឋានច្រកទ្វារទី១ និងនាយកដ្ឋានច្រកទ្វារទី២**

នាយកដ្ឋានច្រកទ្វារទី១ មានវិសាលភាពគ្រប់គ្រងច្រកទ្វារព្រំដែនអន្តរជាតិ ដែលមានព្រំដែនជាប់ជាមួយព្រះរាជាណាចក្រថៃឡង់ដ៍ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ

នាយកដ្ឋានច្រកទ្វារទី២ មានវិសាលភាពគ្រប់គ្រងច្រកទ្វារព្រំដែនអន្តរជាតិ ដែលមានព្រំដែនជាប់ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម និងបណ្តាច្រកទ្វារកំពង់ផែអន្តរជាតិ

នាយកដ្ឋានច្រកទ្វារទាំងពីរខាងលើនេះ មានតួនាទី ភារកិច្ចធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍លើ ៖

-កសាងផែនការសកម្មភាពការងារគ្រប់គ្រងច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិ

-រៀបចំបែបបទលើលិខិតបទដ្ឋាននានាសំដៅបម្រើសេវា ការធ្វើដំណើររបស់អ្នកដំណើរឆ្លងកាត់ច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិ

-ត្រួតពិនិត្យរាល់ឯកសារធ្វើដំណើរ មនុស្ស មធ្យោបាយ ទំនិញ ដែលឆ្លងកាត់ច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិ

-ពិនិត្យស្នើសុំការសម្រេចបដិសេធមិនឲ្យចូល-ចេញប្រទេស ចំពោះអ្នកដំណើរដែលមានឯកសារធ្វើដំណើរមិនប្រក្រតី មិនមានលក្ខណៈគ្រប់គ្រាន់តាមលក្ខខណ្ឌច្បាប់និងអនុវត្តតាមអធិបញ្ញាដើម្បីចាត់វិធានការតាមច្បាប់កំណត់

-ធ្វើការផាកពិន័យចំពោះជនបរទេស ដែលស្នាក់នៅលើសរយៈពេលកំណត់នៃទិដ្ឋាការពេលធ្វើដំណើរចេញ

-គ្រប់គ្រង និងកត់ត្រាទិន្នន័យអ្នកដំណើរមធ្យោបាយ ចូល-ចេញប្រទេសតាមប្រព័ន្ធបច្ចេកវិទ្យា

-សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធនៅច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិ ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាបរាល់បទល្មើសគ្រប់ប្រភេទដែលឆ្លងកាត់ច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិតាមនីតិវិធីច្បាប់

-សហការជាមួយតំណាងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចប្រទេសជិតខាង សំដៅលើកកម្ពស់សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការនៅច្រកទ្វារអន្តរជាតិនិងច្រកទ្វារព្រំដែនអន្តរជាតិអោយបានល្អប្រសើរ

នាយកដ្ឋានច្រកទ្វារទី១ គ្រប់គ្រង ត្រួតពិនិត្យអាកាសយានិក អ្នកបើកបរ បុគ្គលិកធ្វើការលើយន្តហោះ រថយន្ត រថភ្លើងដែលធ្វើដំណើរឆ្លងកាត់ច្រកទ្វាអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិ និងផ្តល់ប័ណ្ណព្រំដែនពណ៌លឿង (Border Pass) ដល់ពលរដ្ឋខ្មែរដែលមានទីលំនៅជាប់ព្រំដែនតាមកិច្ចព្រមព្រៀងរបស់ព្រះរាជាណាចក្រកម្ពុជា និងប្រទេសជិតខាង។

នាយកដ្ឋានច្រកទ្វារទី២ គ្រប់គ្រង ត្រួតពិនិត្យនាវិក អ្នកបើកបរ បុគ្គលិកធ្វើការលើ នាវា រថយន្ត រថភ្លើងដែលធ្វើដំណើរឆ្លងកាត់ច្រកទ្វារព្រំដែនអន្តរជាតិនិងច្រកទ្វារកំពង់ផែអន្តរជាតិ និងចូលរួមអមនាវាពីចំណុចកណ្តាលមកកំពង់ផែអន្តរជាតិ ពីកំពង់ផែអន្តរជាតិទៅកាន់ចំណុចកណ្តាលវិញ និងផ្តល់ប័ណ្ណឡើងគោកដល់នាវិក។

-ធ្វើការងារភស្តុភារ គណនេយ្យ និងការងារបុគ្គលិករបស់នាយកដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានច្រកទ្វារទី១ និងនាយកដ្ឋានច្រកទ្វារទី២ តាមរបបកំណត់ជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ប្រគល់ឲ្យ។

**មាត្រា ១០.-**

**នាយកដ្ឋានស៊ើបអង្កេត និងអនុវត្តនីតិវិធី**

នាយកដ្ឋានស៊ើបអង្កេត និងអនុវត្តនីតិវិធី មានតួនាទីភារកិច្ចធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍លើ ៖

-កសាងផែនការសកម្មភាពរបស់នាយកដ្ឋានទាក់ទងនឹងការស៊ើបអង្កេត និងការអនុវត្តន៍នីតិវិធី

-ទទួលអនុវត្តអធិបញ្ញានានាឬអនុវត្តសំណើផ្លូវការរបស់ស្ថាប័នអន្តរជាតិដែលមានសមត្ថកិច្ចពាក់ព័ន្ធជនបរទេសដែលបានធ្វើសកម្មភាពផ្ទុយនឹងច្បាប់រដ្ឋ ឬច្បាប់នៃប្រទេសដទៃស្របតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិឬកិច្ចព្រមព្រៀងនានា

-លើកសំណើសុំគោលការណ៍វិធានការជាក់ស្តែងជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍លើការងារប្រមូលព័ត៌មានក្នុងមជ្ឈដ្ឋានជនបរទេស និងជនពាក់ព័ន្ធផ្សេងៗទៀតដែលធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ

-ត្រួតពិនិត្យគ្រប់គ្រង និងចាត់វិធានការស្រាវជ្រាវបង្ការទប់ស្កាត់ សកម្មភាពប្រឆាំងសន្តិសុខជាតិ និងបង្ក្រាបរាល់អំពើលួចជ្រៀតចូលស្នាក់នៅ និងប្រកបមុខរបរខុសច្បាប់របស់ជនបរទេស និងជនពាក់ព័ន្ធដើម្បីឃាត់ខ្លួនតាមនីតិវិធីច្បាប់

-គ្រប់គ្រងវត្តមានជនបរទេសជាប្រចាំ និងធ្វើការចង្អុលណែនាំដល់មន្ត្រីអន្តោប្រវេសន៍នៅមូលដ្ឋានរាជធានី-ខេត្តដើម្បីអនុវត្តការងារនេះ

-ពិនិត្យស៊ើបបញ្ជាក់អំពីអត្តសញ្ញាណ និងសាវតាជនបរទេសដែលស្នើសុំរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ

-គ្រប់គ្រងទីកន្លែងត្រៀមបណ្តេញចេញចំពោះជនបរទេសធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គម រង់ចាំការបំពេញបែបបទបណ្តេញចេញ ឬបញ្ជូនទៅតុលាការតាមនីតិវិធីច្បាប់

-ធ្វើការងារភស្តុភារ គណនេយ្យ និងការងារបុគ្គលិករបស់នាយកដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានស៊ើបអង្កេត និងអនុវត្តនីតិវិធីតាមរបបកំណត់ជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ប្រគល់ឲ្យ។

**មាត្រា ១១.-**

**នាយកដ្ឋានជនភៀសខ្លួន**

នាយកដ្ឋានជនភៀសខ្លួន មានតួនាទីភារកិច្ចធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍លើះ

-កសាងផែនការសកម្មភាពលើការងារគ្រប់គ្រងជនភៀសខ្លួន

-ស្នើរៀបចំបែបបទនីតិវិធី និងលិខិតបទដ្ឋានផ្សេងៗសម្រាប់បម្រើឲ្យការងារជនភៀសខ្លួន

-ទទួលពាក្យសុំចុះឈ្មោះជនបរទេសដែលសុំសិទ្ធជ្រកកោន និងឋានៈជាជនភៀសខ្លួន

-ស្នើសុំផ្តល់ និងពន្យាលិខិតអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នជូនដល់ជនបរទេសជាអ្នកសុំសិទ្ធជ្រកកោន

-ស្នើសុំគោលការណ៍សម្រេចកំណត់ឋានៈជាជនភៀសខ្លួន

-ស្នើសុំគោលការណ៍សម្រេចបដិសេធមិនផ្តល់ឋានៈជាជនភៀសខ្លួន ដល់ជនបរទេសសុំសិទ្ធិជ្រកកោន និងមានវិធានការតាមផ្លូវច្បាប់លើការបណ្តេញចេញ

-ទទួលពាក្យបណ្តឹងជំទាស់ និងសម្របសម្រួលដោះស្រាយបាតុភាពផ្សេងៗពាក់ព័ន្ធជនភៀសខ្លួនតាមបញ្ជារបស់ថ្នាក់ដឹកនាំ

-រៀបចំបែបបទផ្តល់ និងស្នើពន្យាសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ឯកសារធ្វើដំណើរ និងទិដ្ឋាការចេញដល់ជនភៀសខ្លួន

-តាមការប្រគល់សិទ្ធិពីអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ សហការជាមួយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននិងសមត្ថកិច្ចពាក់ព័ន្ធដើម្បីចុះធ្វើបច្ចុប្បន្នភាពជនភៀសខ្លួន

-តាមដានត្រួតពិនិត្យដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពនៃការជ្រៀតចូលក្នុងប្រទេសដោយខុសច្បាប់ក្រោមរូបភាពជាជនភៀសខ្លួន

-ធ្វើការងារភស្តុភារ គណនេយ្យ និងការងារបុគ្គលិករបស់នាយកដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋាននាយកដ្ឋានជនភៀសខ្លួនតាមរបបកំណត់ជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ប្រគល់ឲ្យ។

**មាត្រា ១២.-**

នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដឹកនាំដោយប្រធាន ០១រូប និងមានអនុប្រធានមួយចំនួនជាជំនួយតាមការចាំបាច់។

ការរៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងតួនាទីភារកិច្ចរបស់ការិយាល័យនៃនាយកដ្ឋានចំណុះអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៨៤.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការកែសម្រួលមាត្រា ៥ នៃអនុក្រឹត្យ លេខ១៥៨អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីតួនាទី ភារកិច្ច របៀបរបបធ្វើការងារនៃអគ្គនាយកដ្ឋាន /

អត្តសញ្ញាណកម្ម និងបណ្តានាយកដ្ឋានចំណុះ ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រងការងារអត្តសញ្ញាណកម្មប្រជាពលរដ្ឋ ដើម្បីជានាលើកកំពស់ការគោរពសិទ្ធិសេរីភាព និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ធានាការគោរពសិទ្ធិមនុស្ស លិទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ បំរើឲ្យការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ព្រមទាំងរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពលើការងារអត្តសញ្ញាណកម្មប្រជាពលរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី២
## តួនាទី ភារកិច្ច របស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

**មាត្រា ៤.-**

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានតួនាទី ធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃលើការងារអត្តសញ្ញាណកម្មប្រជាពលរដ្ឋ និងមានភារកិច្ចដូចតទៅ៖

-សិក្សារៀបចំតាក់តែង សេចក្តីព្រាងច្បាប់ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងការងារអត្រានុកូលដ្ឋាន ការងារស្ថិតិប្រជាពលរដ្ឋ ការងារស្នាក់នៅ ការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការងារលិខិតឆ្លងដែនធម្មតា ការងារលិខិតធ្វើដំណើរឆ្លងដែនដទៃទៀត និងការងារសញ្ជាតិ

-សិក្សា និងរៀបចំគោលការណ៍ វិធានការ យន្តការ បែបបទ និងនីតិវិធីនៃការផ្តល់ឯកសារអត្រានុកូលដ្ឋាន សម្គាល់ការស្នាក់នៅ សម្គាល់គ្រួសារ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតឆ្លងដែនធម្មតា លិខិតធ្វើដំណើរឆ្លងដែនដទៃទៀត និងការផ្តល់ឬការលះបង់សញ្ជាតិខ្មែរ

-ធ្វើបច្ចុប្បន្នភាពលើការងារអត្រានុកូលដ្ឋាន ការងារស្ថិតិប្រជាពលរដ្ឋ ការងារស្នាក់នៅ ការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការងារលិខិតឆ្លងដែនធម្មតា លិខិតធ្វើដំណើរឆ្លងដែនដទៃទៀត និងការងារសញ្ជាតិឲ្យស្របទៅតាមការវិវឌ្ឍន៍នៃសកលភាវូបនីយកម្ម

-គ្រប់គ្រងការងារអត្តសញ្ញាណប្រជាពលរដ្ឋ ការងារអត្រានុកូលដ្ឋាន ការងារស្ថិតិប្រជាពលរដ្ឋ ការងារស្នាក់នៅរបស់ប្រជាពលរដ្ឋខ្មែរនិងជនបរទេស ការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការងារលិខិតឆ្លងដែនធម្មតា លិខិតធ្វើដំណើរឆ្លងដែនដទៃទៀត និងការងារសញ្ជាតិស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តកំណត់

-គ្រប់គ្រង ត្រួតពិនិត្យការងាររៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

-ធ្វើការពិនិត្យ និងចេញឯកសារបញ្ជាក់អំពីអត្តសញ្ញាណរបស់ប្រជាពលរដ្ឋ

-រៀបចំ គ្រប់គ្រង ទុកដាក់ ថែរក្សា និងប្រើប្រាស់ទិន្នន័យស្តីអំពីអត្តសញ្ញាណប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា

-រៀបចំផែនការ និងលើកគម្រោងថវិកា មធ្យោបាយ សម្ភារៈសំរាប់ការងារ អត្តសញ្ញាណកម្ម

-ដឹកនាំ គ្រប់គ្រងការងារបុគ្គលិក ភស្តុភារ គណនេយ្យរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងបណ្តានាយកដ្ឋានចំណុះ

-សម្របសម្រួល សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋាននានាចំណុះក្រសួងមហាផ្ទៃ ដើម្បីបំពេញភារកិច្ចតាមតួនាទីភារកិច្ចរបស់ខ្លួន

-ដឹកនាំ គ្រប់គ្រងមន្ត្រីអត្តសញ្ញាណកម្មទាំងនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងមន្ត្រីបំរើការងារអត្តសញ្ញាណកម្មនៅថ្នាក់ក្រោមជាតិ អនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្ត

-ស្នើតែងតាំង ឬផ្លាស់ប្តូរភារកិច្ច លើកសរសើរ និងការអនុវត្តវិន័យមន្ត្រីរបស់អគ្គនាយក-ដ្ឋានអត្តសញ្ញាណកម្ម ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យសំរេច

-តាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មអាចសហការជាមួយក្រសួង ស្ថាប័ន និងសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ដើម្បីបំរើសំណូមពរបញ្ជាក់អត្តសញ្ញាណរបស់ជនរងគ្រោះ ជនសង្ស័យ និងជនបាត់ខ្លួន

-រៀបចំផែនការបណ្តុះបណ្តាល កសាងធនធានមនុស្ស ដើម្បីពង្រឹងសមត្ថភាពជំនាញ វិជ្ជាជីវៈ ភាសាបរទេសដល់មន្ត្រីអត្តសញ្ញាណកម្ម

-តាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មអាចទំនាក់ទំនង និងសហការជាមួយអង្គការជាតិ អង្គការអន្តរជាតិ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ បណ្តាប្រទេសជាមិត្ត និងវិស័យឯកជននានា ដើម្បីជំរុញ និងពង្រឹងការអនុវត្តការងាររបស់ខ្លួន

-ស្រាវជ្រាវអង្កេត វាយតម្លៃភាពមិនប្រក្រតីនៃការងារអត្តសញ្ញាណកម្ម

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មតាមរបបកំណត់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បំពេញភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់ជូន ។

## ជំពូកទី៣

## តួនាទី ភារកិច្ច បណ្តានាយកដ្ឋាន
## ចំណុះអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

**មាត្រា ៥.-**

**នាយកដ្ឋានរដ្ឋបាលសរុប**

-នាយកដ្ឋានរដ្ឋបាលសរុប មានតួនាទីធ្វើជាសេនាធិការ លើការងាររដ្ឋបាល រួមមានការចាត់ចែងឯកសារនានា ការរៀបចំកិច្ចប្រជុំ សន្និបាត សិក្ខាសាលា រួមទាំងការធ្វើកំណត់ហេតុ ឬរបាយការណ៍លទ្ធផលនៃការប្រជុំ ការងារពិធីការ ការគ្រប់គ្រងត្រា ការងារប័ណ្ណសារ ធ្វើរបាយការណ៍បូកសរុប និងទិសដៅការងារ តាមរបបកំណត់ និងមានភារកិច្ចដូចតទៅ៖

-ធ្វើការងារសម្របសម្រួលជាមួយបណ្តានាយកដ្ឋានសមត្ថកិច្ចចំណុះអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្នុងការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងដល់ការងារអត្តសញ្ញាណប្រជាពលរដ្ឋ

-ធ្វើកិច្ចសហការជាមួយបណ្តានាយកដ្ឋានពាក់ព័ន្ធ លើកផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ឬកម្មវិធីការងាររបស់អគ្គនាយកដ្ឋាន

-ធ្វើកិច្ចការទំនាក់ទំនងសាធារណៈ

-សហការជាមួយអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងការប្រមូលចំណូលថវិកាជាតិពីការងារអត្តសញ្ញាណកម្មតាមការកំណត់

-ធ្វើការងារភស្តុភារ គណនេយ្យ និងការងារបុគ្គលិកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មប្រគល់ឲ្យ ។

**មាត្រា ៦.-**

**នាយកដ្ឋានអត្រានុកូលដ្ឋាន**

-នាយកដ្ឋានអត្រានុកូលដ្ឋាន មានតួនាទីធ្វើជាសេនាធិការ លើការងារអត្រានុកូលដ្ឋាន ដោយសិក្សារៀបចំគោលការណ៍ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ក្នុងការចុះបញ្ជី និងផ្តល់សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍សំបុត្រមរណៈភាព និងមានភារកិច្ចដូចតទៅ៖

-ធ្វើការងារកសាងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីធ្វើជាមូលដ្ឋានឯកភាពដល់ឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតរបស់ប្រជាពលរដ្ឋ

-ធ្វើការងារដឹកនាំ ត្រួតពិនិត្យ លើកិច្ចដំណើរការការងារនៃមន្ត្រីអត្រានុកូលដ្ឋាន ព្រមទាំងលើកគម្រោងផែនការ កម្មវិធីបណ្តុះបណ្តាលមន្ត្រីអត្រានុកូលដ្ឋាន

-ធ្វើការងារបោះពុម្ព ការគ្រប់គ្រង ការបែងចែកសៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋាន

-ធ្វើការងារពិនិត្យនីត្យានុកូលភាពនៃឯកសារអត្រានុកូលដ្ឋាន និងចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋតាមការស្នើសុំ

-ធ្វើការងារពិនិត្យ និងលើកយោបល់លើសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

-ធ្វើការងារអប់រំ ផ្សព្វផ្សាយជាសាធារណៈជូនប្រជាពលរដ្ឋអំពីការងារអត្រានុកូលដ្ឋាន

-សហការកសាងផែនការប្រឆាំងឧក្រិដ្ឋកម្មបច្ចេកវិទ្យា និងការពារហានិភ័យផ្សេងៗទៀត ដើម្បីការពារសន្តិសុខ សុវត្ថិភាព ប្រព័ន្ធ និងទិន្នន័យនៃអត្រានុកូលដ្ឋាន

-គ្រប់គ្រងចំណូលពីការងារអត្រានុកូលដ្ឋានតាមច្បាប់ជាធរមាន

-ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ការងារបណ្តុះបណ្តាល និងការងារភស្តុភារ គណនេយ្យរបស់នាយកដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានអត្រានុកូលដ្ឋានតាមរបបកំណត់

-ធ្វើការងារបណ្ណសាររបស់នាយកដ្ឋាន

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មប្រគល់ឲ្យ ។

**មាត្រា ៧.–**

នាយកដ្ឋានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

-នាយកដ្ឋានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានតួនាទីធ្វើជាសេនាធិការ ក្នុងការសិក្សារៀបចំគោលការណ៍ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពការងារអត្តសញ្ញាណ-ប័ណ្ណសញ្ជាតិខ្មែរ និងមានភារកិច្ចដូចតទៅ៖

-ធ្វើការងារដឹកនាំ ចាត់ចែងការស្រង់ ប្រមូលទិន្នន័យប្រជាពលរដ្ឋដែល ត្រូវផ្តល់អត្ត-សញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងការចែកផ្តល់អត្ត-សញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ

-ធ្វើការងារអប់រំ ផ្សព្វផ្សាយជាសាធារណៈជូនប្រជាពលរដ្ឋអំពីការងារអត្តសញ្ញាណប័ណ្ណ-សញ្ជាតិខ្មែរ

-ធ្វើការសាងប្រព័ន្ធគ្រប់គ្រងរក្សាទុកទិន្នន័យ ចុះបញ្ជីការងារអត្តសញ្ញាណប័ណ្ណតាមប្រព័ន្ធបច្ចេកវិទ្យា

-ធ្វើការងារត្រួតពិនិត្យនីត្យានុកូលភាពនៃអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

-ធ្វើការងារដឹកនាំ ត្រួតពិនិត្យ លើកិច្ចដំណើរការការងារនៃមន្ត្រីអត្តសញ្ញាណប័ណ្ណ ព្រមទាំងលើកគម្រោងផែនការ កម្មវិធីបណ្តុះបណ្តាលមន្ត្រីអត្តសញ្ញាណប័ណ្ណ

-សហការកសាងផែនការប្រឆាំងឧក្រិដ្ឋកម្មបច្ចេកវិទ្យា និងការពារហានិភ័យផ្សេងៗទៀត ដើម្បីការពារសន្តិសុខ សុវត្ថិភាព ប្រព័ន្ធ និងទិន្នន័យនៃអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

-គ្រប់គ្រងចំណូលពីការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរតាមច្បាប់ជាធរមាន

-ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ការងារបណ្តុះបណ្តាល និងការងារភស្តុភារ គណនេយ្យរបស់នាយកដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានសញ្ជាតិខ្មែរតាមរបបកំណត់

-ធ្វើការងារបណ្ណសាររបស់នាយកដ្ឋាន

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មប្រគល់ឲ្យ ។

**មាត្រា ៨._**

**នាយកដ្ឋានលិខិតឆ្លងដែន**

-នាយកដ្ឋានលិខិតឆ្លងដែន មានតួនាទីធ្វើជាសេនាធិការ ក្នុងការសិក្សារៀបចំគោលការណ៍ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពការងារលិខិតឆ្លងដែនធម្មតា និងលិខិតធ្វើដំណើរឆ្លងដែនដទៃទៀត និងមានភារកិច្ចដូចតទៅ៖

-ធ្វើការងារដឹកនាំ ចាត់ចែងប្រមូលទិន្នន័យប្រជាពលរដ្ឋដែលស្នើសុំលិខិតឆ្លងដែនធម្មតាការផលិតលិខិតឆ្លងដែនធម្មតា និងការចែកផ្តល់លិខិតឆ្លងដែនធម្មតាជូនប្រជាពលរដ្ឋ

-ធ្វើការងាររៀបចំបែបបទ នីតិវិធីនៃការផ្តល់លិខិតឆ្លងដែនធម្មតា និងការគ្រប់គ្រងច្រកចេញចូលតែមួយ

-ធ្វើការងារដឹកនាំ ត្រួតពិនិត្យ ការផ្តល់លិខិតឆ្លងដែនធម្មតា តាមសាខាលិខិតឆ្លងដែនប្រចាំតំបន់

-ធ្វើការងាររៀបចំលិខិតបទដ្ឋានក្នុងការផ្តល់លិខិតធ្វើដំណើរឆ្លងដែនដទៃទៀត

-ធ្វើការងារអប់រំ ផ្សព្វផ្សាយជាសាធារណៈជូនប្រជាពលរដ្ឋអំពីការងារលិខិតឆ្លងដែនធម្មតា និងលិខិតធ្វើដំណើរឆ្លងដែនដទៃទៀត

-ធ្វើការងារកសាងប្រព័ន្ធគ្រប់គ្រងរក្សាទុកទិន្នន័យ ចុះបញ្ជីការងារលិខិតឆ្លងដែនធម្មតាតាមប្រព័ន្ធបច្ចេកវិទ្យា

-ធ្វើការងារត្រួតពិនិត្យនីត្យានុកូលភាពនៃលិខិតឆ្លងដែនធម្មតា និងលិខិតធ្វើដំណើរឆ្លងដែនដទៃទៀត

-ធ្វើការងារដឹកនាំ ត្រួតពិនិត្យលើកិច្ចដំណើរការការងារនៃមន្ត្រីលិខិតឆ្លងដែនធម្មតា ព្រមទាំងលើកគម្រោងផែនការ កម្មវិធីបណ្តុះបណ្តាលមន្ត្រីលិខិតឆ្លងដែនធម្មតា

-សហការកសាងផែនការប្រឆាំងឧក្រិដ្ឋកម្មបច្ចេកវិទ្យា និងការពារហានិភ័យផ្សេងៗទៀតដើម្បីការពារសន្តិសុខ សុវត្ថិភាព ប្រព័ន្ធ និងទិន្នន័យរបស់នាយកដ្ឋាន

-គ្រប់គ្រងចំណូលពីការងារលិខិតឆ្លងដែនធម្មតាតាមច្បាប់ជាធរមាន

-ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ការងារបណ្តុះបណ្តាល និងការងារភស្តុភារ គណនេយ្យ របស់នាយកដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានលិខិតឆ្លងដែន តាមរបបកំណត់

-ធ្វើការងារបណ្ណសាររបស់នាយកដ្ឋាន

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មប្រគល់ឲ្យ ។

**មាត្រា ៩.-**

នាយកដ្ឋានសញ្ជាតិ

-នាយកដ្ឋានសញ្ជាតិ មានតួនាទីធ្វើជាសេនាធិការ ក្នុងការអនុវត្តច្បាប់ស្តីពីសញ្ជាតិ អនុក្រឹត្យ និងលិខិតបទដ្ឋានពាក់ព័ន្ធ និងមានភារកិច្ចដូចតទៅៈ

-ធ្វើការងារកសាងខ្លឹមសារឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការងារសញ្ជាតិ

-ធ្វើការងារពិនិត្យ លើកយោបល់លើសំណុំឯកសារស្នើសុំចូលសញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ឬការទាមទារសញ្ជាតិ និងការប្តឹងជំទាស់ចំពោះការទាមទារសញ្ជាតិ

-ធ្វើការងារពិនិត្យ លើកយោបល់លើសំណុំឯកសារសុំលះបង់សញ្ជាតិ

-ធ្វើការងាររៀបចំសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទៅនាយករដ្ឋមន្ត្រី និងសំណើរបស់នាយករដ្ឋមន្ត្រីថ្វាយព្រះមហាក្សត្រ និងរៀបចំព្រះរាជក្រឹត្យ

-ធ្វើការងាររៀបចំបែបបទ នីតិវិធីនៃការប្រកាសចូលសញ្ជាតិ

-គ្រប់គ្រងទិន្នន័យជនដែលទទួលបានសញ្ជាតិខ្មែរ និងលះបង់សញ្ជាតិខ្មែរ តាមព្រះរាជក្រឹត្យ

-ធ្វើការងារត្រួតពិនិត្យនីត្យានុកូលភាពនៃការងារសញ្ជាតិខ្មែរ

-ធ្វើការងារដឹកនាំ ត្រួតពិនិត្យ លើកិច្ចដំណើរការការងារនៃមន្ត្រីនាយកដ្ឋានសញ្ជាតិ ព្រមទាំងលើកគម្រោងផែនការ កម្មវិធីបណ្តុះបណ្តាលមន្ត្រីនៃនាយកដ្ឋានសញ្ជាតិ

-គ្រប់គ្រងចំណូលពីការងារសញ្ជាតិតាមច្បាប់ជាធរមាន

-ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ការងារបណ្តុះបណ្តាល និងការងារភស្តុភារ គណនេយ្យ របស់នាយកដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានសញ្ជាតិតាម របបកំណត់

-ធ្វើការងារបណ្ណសាររបស់នាយកដ្ឋាន

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មប្រគល់ឲ្យ ។

**មាត្រា ១០.-**

នាយកដ្ឋានស្ថិតិប្រជាពលរដ្ឋ

-នាយកដ្ឋានស្ថិតិប្រជាពលរដ្ឋ មានតួនាទីជាសេនាធិការ លើការងារស្ថិតិប្រជាពលរដ្ឋ ដោយសិក្សារៀបចំគោលការណ៍ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការ សកម្មភាព និងរៀបចំលិខិតបទដ្ឋានគតិយុត្តិនានាក្នុងការចុះបញ្ជីស្ថិតិប្រជាពលរដ្ឋការផ្តល់ឯកសារសម្គាល់ការស្នាក់នៅ សម្គាល់គ្រួសារ ការផ្លាស់ប្តូរទីលំនៅ និងមានភារកិច្ចដូចតទៅ៖

-ធ្វើការងារដឹកនាំ ចាត់ចែងការស្រង់ ប្រមូលទិន្នន័យស្ថិតិប្រជាពលរដ្ឋដែលត្រូវផ្តល់ឯកសារសម្គាល់ការស្នាក់នៅ ឯកសារសម្គាល់គ្រួសារ និងឯកសារផ្លាស់ប្តូរទីលំនៅជូនប្រជាពលរដ្ឋ

-ធ្វើការងារដឹកនាំ ត្រួតពិនិត្យ លើកិច្ចដំណើរការការងារ នៃមន្ត្រីស្ថិតិប្រជាពលរដ្ឋ ព្រមទាំងលើកគម្រោងផែនការ កម្មវិធីបណ្តុះបណ្តាលមន្ត្រីស្ថិតិប្រជាពលរដ្ឋ

-ធ្វើការងារបោះពុម្ព ការគ្រប់គ្រងនិងការបែងចែកក្រដាសស្នាមគ្រប់ប្រភេទសម្រាប់ចុះបញ្ជីប្រជាពលរដ្ឋ ឯកសារសម្គាល់ការស្នាក់នៅ ឯកសារ សម្គាល់គ្រួសារ និងឯកសារផ្លាស់ប្តូរទីលំនៅដល់មន្ត្រីស្ថិតិប្រជាពលរដ្ឋ

-ធ្វើការងារអប់រំ ផ្សព្វផ្សាយជាសាធារណៈជូនប្រជាពលរដ្ឋអំពីការងារស្ថិតិប្រជាពលរដ្ឋ

-ធ្វើការងារកសាងប្រព័ន្ធគ្រប់គ្រងរក្សាទុកទិន្នន័យ ចុះបញ្ជីស្ថិតិប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យា

-ធ្វើការងារពិនិត្យនីត្យានុកូលភាពនៃឯកសារសម្គាល់ការស្នាក់នៅឯកសារសម្គាល់គ្រួសារ និងឯកសារផ្លាស់ប្តូរទីលំនៅ

-សហការកសាងផែនការប្រឆាំងឧក្រិដ្ឋកម្មបច្ចេកវិទ្យា និងការពារហានិភ័យផ្សេងៗទៀត ដើម្បីការពារសន្តិសុខ សុវត្ថិភាព ប្រព័ន្ធ និងទិន្នន័យស្ថិតិប្រជាពលរដ្ឋ

-គ្រប់គ្រងចំណូលពីការងារស្ថិតិប្រជាពលរដ្ឋតាមច្បាប់ជាធរមាន

-ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ការងារបណ្តុះបណ្តាល និងការងារកស្តុការ គណនេយ្យរបស់នាយកដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានស្ថិតិប្រជាពលរដ្ឋតាមរបបកំណត់

-ធ្វើការងារបណ្ណសាររបស់នាយកដ្ឋាន

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មប្រគល់ឲ្យ

**មាត្រា ១១.-**

នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា

-នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា មានតួនាទីធ្វើជាសេនាធិការ ក្នុងការសិក្សារៀបចំ គោលការណ៍ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ការងារគ្រប់គ្រង ប្រើប្រាស់ វិភាគ បែងចែកប្រភេទទិន្នន័យអត្តសញ្ញាណប្រជាពលរដ្ឋទៅតាមលក្ខណៈ វិទ្យាសាស្ត្រ និង អភិវឌ្ឍន៍បច្ចេកវិទ្យាទូរគមនាគមន៍ព័ត៌មានវិទ្យា និងមានភារកិច្ចដូចតទៅ៖

-ធ្វើការងារដឹកនាំ ចាត់ចែងការស្រង់ ប្រមូលទិន្នន័យអត្តសញ្ញាណប្រជាពលរដ្ឋដែលបញ្ជូន ពីបណ្តានាយកដ្ឋានចំណុះអគ្គនាយកដ្ឋាន

-ធ្វើការងាររៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យអត្តសញ្ញាណអេឡិចត្រូនិចស្តង់ដារ សំរាប់ប្រើប្រាស់ ក្នុងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មធានាបាននូវសង្គតិភាពក្នុងការបញ្ចូល ថែរក្សា គ្រប់គ្រង និងប្រើប្រាស់ទិន្នន័យអត្តសញ្ញាណកម្មតាមការចាំបាច់

-តាមការប្រគល់សិទ្ធិពីអគ្គនាយក ធ្វើកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ដើម្បី ប្រមូល និងចែករំលែកទិន្នន័យព័ត៌មានវិទ្យាតាមការចាំបាច់

-ធ្វើការងារដឹកនាំ ត្រួតពិនិត្យ លើកិច្ចដំណើរការការងារនៃមន្ត្រីព្រមទាំងលើកគម្រោង ផែនការកម្មវិធីបណ្តុះបណ្តាលមន្ត្រី របស់នាយកដ្ឋានគ្រប់គ្រងពត៌មានវិទ្យា

-ធ្វើការងារកសាងផែនការប្រឆាំងឧក្រិដ្ឋកម្មបច្ចេកវិទ្យា និងការពារហានិភ័យផ្សេងៗទៀត ដើម្បី ការពារសន្តិសុខ សុវត្ថិភាព ប្រព័ន្ធ និងទិន្នន័យនៃអត្តសញ្ញាណប្រជាពលរដ្ឋ

-ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ការងារបណ្តុះបណ្តាល និងការងារភស្តុភារ គណនេយ្យ របស់នាយកដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធ ព័ត៌មានវិទ្យាតាមរបបកំណត់

-ធ្វើការងារបណ្ណសាររបស់នាយកដ្ឋាន

-បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មប្រគល់ឲ្យ ។

**មាត្រា ១២.-**

នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដឹកនាំដោយប្រធាន ០១រូប និងមានអនុប្រធាន មួយចំនួនជាជំនួយតាមការចាំបាច់ ។

ការរៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងតួនាទី ភារកិច្ចរបស់ការិយាល័យនៃនាយកដ្ឋានចំណុះ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ដើម្បីចុះហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត**

**លេខាធិការដ្ឋាន**

លេខ : ..៧៤...គសអ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតលេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី ២ ឆ្នាំ ២០១៤

## ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១១ ស្ដីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ២០១១-២០១៤
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ និងច្បាប់ ស្ដីពីវិសោធនកម្មនៃនេះ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងផែនការអន្តរស្ថាប័ន លេខ ០១៤ ផ.ក/១១ ចុះថ្ងៃទី ២៣-០៨-២០១១ រវាងក្រសួងមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប ស្ដីពី កិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សម្រាប់ដំណើរការរៀបចំការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ២០១១-២០១៤
- យោងតាមការចាំបាច់ ។

## សម្រេច

ប្រការ ១.- ត្រូវបានបង្កើតលេខាធិការដ្ឋានរបស់ គ.ស.អ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី ២ ឆ្នាំ២០១៤ ដែលមានសមាសភាព ដូចតទៅ ៖

១- ឯកឧត្ដម នាយឧត្ដមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ ប្រធាន

| | | | | |
|---|---|---|---|---|
| ២- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **មាស សុផា** | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក | អនុប្រធាន |
| ៣- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **សឿង សំណាង** | មេបញ្ជាការកងទ័ពជើងអាកាស | សមាជិក |
| ៤- | ឯកឧត្តម នាយឧត្តមនាវី | **ទៀ វិញ** | មេបញ្ជាការកងទ័ពជើងទឹក | សមាជិក |
| ៥- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **ខៀវ សុផ័ត** | អគ្គលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **យុន ឈុន្នី** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៧- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **គៀត ច័ន្ទថារិទ្ធ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៨- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ជោង លីម** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៩- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឆៃ ស៊ីណារិទ្ធ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១០- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឯម សំណាង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ | សមាជិក |
| ១១- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ទៀ សីហា** | នាយរងសេនាធិការចម្រុះ និងជានាយកទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន | សមាជិក |
| ១២- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ហៅ សុផាន់** | នាយរងសេនាធិការចម្រុះ និងជាមេបញ្ជាការកងពលតូចលេខ៧០ អគ្គបញ្ជាការដ្ឋាន | សមាជិក |
| ១៣- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ទៀ ពិសេន** | មេបញ្ជាការរង និងជានាយសេនាធិការបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៤- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ព្រហ្ម ឌិន** | មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគពិសេស | សមាជិក |
| ១៥- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ហួត ឈាន** | មេបញ្ជាការរងកងទ័ពជើងគោកនិងជាមេបញ្ជាការយោធភូមិភាគទី១ | សមាជិក |
| ១៦- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ជឿន សុវណ្ណថា** | មេបញ្ជាការរងកងទ័ពជើងគោកនិងជាមេបញ្ជាការយោធភូមិភាគទី២ | សមាជិក |
| ១៧- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **យឿង សុខុន** | មេបញ្ជាការរងកងទ័ពជើងគោកនិងជាមេបញ្ជាការយោធភូមិភាគទី៣ | សមាជិក |
| ១៨- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ជា ម៉ន** | មេបញ្ជាការរងកងទ័ពជើងគោកនិងជាមេបញ្ជាការយោធភូមិភាគទី៤ | សមាជិក |
| ១៩- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ប៊ុន សេង** | មេបញ្ជាការរងកងទ័ពជើងគោកនិងជាមេបញ្ជាការយោធភូមិភាគទី៥ | សមាជិក |
| ២០- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ម៉ក់ ជីតូ** | ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ | សមាជិក |
| ២១- | លោក ឧត្តមសេនីយ៍ទោ | **ឆាយ គីមខឿន** | ប្រធានសេនាធិការដ្ឋាន | សមាជិក |

| | | | |
|---|---|---|---|
| ២២- លោក ឧត្តមសេនីយ៍ទោ | **សោរ៉ាន់ គំសត់** | ប្រធាននាយកដ្ឋានសរុប-ផែនការ | សមាជិក |
| ២៣- លោកឧត្តមសេនីយ៍ទោ | **អ៊ិន ម្ញូរ៉ា** | ប្រធាននាយកដ្ឋានព្រហ្មទណ្ឌ | សមាជិក |
| ២៤- លោកឧត្តមសេនីយ៍ទោ | **ម៉ៅញ គំសោត្ត** | ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ | សមាជិក |
| ២៥- លោកឧត្តមសេនីយ៍ទោ | **អ៊ី សុខឃី** | ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម | សមាជិក |
| ២៦- លោកឧត្តមសេនីយ៍ត្រី | **សៀង សេន** | ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង | សមាជិក |
| ២៧- លោក | **យ៉េត ទីណែល** | អនុប្រធាននាយកដ្ឋានថវិកានីយកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ២៨- លោក | **រ័ត្ន សំ** | អនុប្រធាននាយកដ្ឋានហិរញ្ញកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៩- អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត | | ប្រធានគណៈបញ្ជាការឯកភាពរាជធានី ខេត្ត | សមាជិក |

ប្រការ ២.- លេខាធិការដ្ឋានរបស់ គ.ស.អ មានតួនាទីភារកិច្ច ដូចតទៅ ៖

- ជួយប្រធាន គ.ស.អ ក្នុងផ្សព្វផ្សាយ តាមដាន និងចាត់តាំងអនុវត្តច្បាប់ ផែនការអន្តរស្ថាប័ន លេខ ០១៤ ផ.ក/១១ ចុះថ្ងៃទី ២៣-០៨-២០១១ រវាងក្រសួងមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប ស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ដំណើរការរៀបចំការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ ២០១១-២០១៤ ។
- ផ្សព្វផ្សាយផែនការ ផែនការសកម្មភាព បទបញ្ជា និងសេចក្តីណែនាំផ្សេងៗរបស់ គ.ស.អ ទៅស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ ទៅគ្រប់រចនាសម្ព័ន្ធសន្តិសុខ និងអាជ្ញាធរដែនដីរាជធានី ខេត្ត ។
- ត្រួតពិនិត្យការចាត់តាំងកម្លាំងប្រតិបត្តិការការពារការបោះឆ្នោត ផ្អែកតាមផែនការកំណត់ ។
- ប្រមូលផ្តុំព័ត៌មានពីបណ្តាស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ និងពីគណៈអភិបាល ឬគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ដើម្បីរាយការណ៍ជូនប្រធាន គ.ស.អ ។
- ធ្វើរបាយការណ៍ ស្តីពីសន្តិសុខបោះឆ្នោតជូនប្រធាន គ.ស.អ ។
- រៀបចំសន្និបាតផ្សព្វផ្សាយ ឬកិច្ចប្រជុំការងារ ធ្វើលិខិតអញ្ជើញគ្រប់សមាជិករបស់ គ.ស.អ ទាំងអស់តាមការសម្រេចរបស់ប្រធាន គ.ស.អ ។
- លើកគម្រោងថវិកា ឧបករណ៍ សម្ភារ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ សម្រាប់បម្រើឲ្យការងារសន្តិសុខបោះឆ្នោត ដើម្បីដាក់ជូនប្រធាន គ.ស.អ ពិនិត្យសម្រេច ។
- ប្រមូលផ្តុំ ចាត់ចែង ប្រើប្រាស់សម្ភារ ឧបករណ៍ និងមធ្យោបាយគ្រប់ប្រភេទរបស់បណ្តាអង្គភាពផ្ទាល់ដែលមានស្រាប់ ដើម្បីបម្រើកិច្ចប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ឲ្យបានល្អប្រសើរនៅក្នុងអំឡុងពេលនៃដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងមូល ។
- ចាត់ចែងផ្តល់ថវិកាបំប៉នជូនកម្លាំងការពារតាមគោលដៅ និងធ្វើគម្រោងបែងចែកនូវឧបករណ៍ សម្ភារ និងមធ្យោបាយផ្សេងៗឲ្យបានសមស្របដល់មុខសញ្ញា និងគោលដៅតាមការចាំបាច់ ។
- ធ្វើរបាយការណ៍ថវិកា ការប្រើប្រាស់ឧបករណ៍ សម្ភារ និងមធ្យោបាយគ្រប់ប្រភេទ ប្រចាំខែជូនប្រធាន គ.ស.អ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល ។
- ផ្សព្វផ្សាយនៅក្នុង និងទៅក្រៅប្រទេសនូវព័ត៌មានទាំងឡាយណាដែលពិនិត្យឃើញថាចាំបាច់ត្រូវផ្សព្វផ្សាយជាបន្ទាន់ជូនដល់សាធារណៈមតិជាតិ-អន្តរជាតិ ឲ្យបានយល់ និងជ្រួតជ្រាប ។

ប្រការ ៣.- លេខាធិការដ្ឋានរបស់ គ.ស.អ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ សម្រាប់រាល់កិច្ចការក្នុងវិស័យរដ្ឋបាល និងលិខិតស្នាមផ្លូវការផ្សេងៗរបស់ខ្លួន ។

ប្រការ ៤.- ករណីចាំបាច់ ប្រធានលេខាធិការដ្ឋានរបស់ គ.ស.អ អាចបង្កើតក្រុមប្រចាំការអចិន្ត្រៃយ៍ជាជំនួយការក្នុងកិច្ចការរដ្ឋបាល និងការងារទំនាក់ទំនងផ្សេងៗទៀត ។

ប្រការ ៥.- សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៦.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៤

**ប្រធានគណៈកម្មការសន្តិសុខអចិន្ត្រៃយ៍**
**សម្រាប់ការបោះឆ្នោត**

**ស ខេង**

**<u>កន្លែងទទួល</u> ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ដូចប្រការ ១ និងប្រការ ៦
- គ្រប់គណៈបញ្ជាការឯកភាពរាជធានី ខេត្ត
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ (SSD)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៥ សសរ

# សេចក្តីសម្រេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំកំពូលលើកទី៤របស់ប្រមុខរដ្ឋ/រដ្ឋាភិបាលនៃសន្និសីទស្តីពីអន្តរសកម្ម និងវិធានការកសាងទំនុកចិត្តនៅអាស៊ី នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៤ រហូតដល់ពេលសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងឯកឧត្តម **ស ខេង** ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

លេខ [illegible] សហវ.[illegible]

# ប្រកាស
## ស្តីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១៤

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញក្រឹត្យលេខ ២៨/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤ លើលិខិតលេខ២៦១៥ សហវ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១៤

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ ត្រូវប្រមូលចាប់ពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ។

**ប្រការ ២.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ នៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅធនាគារកាណាឌីយ៉ា ក.អ កម្ពុជា ឬនៅធនាគារអេស៊ីលីដា ភីអិលស៊ី ដោយត្រូវបំពេញលិខិតប្រកាសបង់ពន្ធចំនួន ០២ សន្លឹក តាមទម្រង់ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ ។ ដោយឡែក ទោចក្រយានយន្ត និងត្រីចក្រយានយន្តដែលបំពាក់ដោយម៉ាស៊ីនម៉ូតូ មិនមានកាតព្វកិច្ចបំពេញលិខិតប្រកាស និងមិនចាំបាច់ភ្ជាប់មកជាមួយនូវឯកសារផ្សេងៗទេ ។

ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ មានជម្រើសអាចស្នើសុំធ្វើអត្តសញ្ញាណប័ណ្ណសម្គាល់ការបង់ពន្ធយានយន្តរបស់ខ្លួន ដើម្បីប្រើប្រាស់ក្នុងការបង់ពន្ធសម្រាប់ឆ្នាំសារពើពន្ធខាងមុខទៀតបាន ដោយត្រូវគូសក្នុងប្រអប់ដូចមានបង្ហាញក្នុងលិខិតប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ ។ ការបង្កើតប័ណ្ណនេះឡើងគឺក្នុងបំណងបង្កលក្ខណៈងាយស្រួលក្នុងការបង់ពន្ធ ដោយម្ចាស់យានយន្តមិនចាំបាច់បំពេញលិខិតប្រកាសបង់ពន្ធ សាជាថ្មី ។ ការផ្តល់សេវាធ្វើអត្តសញ្ញាណប័ណ្ណសម្គាល់ការបង់ពន្ធយានយន្តនេះមាននៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅតាមសាខាធនាគារកាណាឌីយ៉ា ក.អ កម្ពុជា ឬនៅតាមសាខាធនាគារអេស៊ីលីដា ភីអិលស៊ី ក្នុងតម្លៃ ៥,០០០រៀល ។

**ប្រការ ៣.-** ក្នុងពេលដាក់លិខិតប្រកាសបង់ពន្ធ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវភ្ជាប់មកជាមួយនូវ ៖

- ប័ណ្ណសម្គាល់យានយន្ត ឬ
- វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ឬ
- បង្កាន់ដៃបង់ពន្ធនាំចូល ឬលិខិតបញ្ជាក់ការប្រើប្រាស់យានយន្តដែលចេញដោយមេឃុំ/ចៅសង្កាត់ចំពោះយានយន្តដែលពុំទាន់បានចុះបញ្ជី និង
- អត្តសញ្ញាណប័ណ្ណសំគាល់ខ្លួនរបស់ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ឬលិខិតឆ្លងដែន ឬអាចលិខិតបញ្ជាក់សំបុត្រកំណើតចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ។

**ប្រការ ៤.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់ទៅតាមប្រភេទនីមួយៗ ដោយមិនគិតថាជាកម្មសិទ្ធិរបស់រដ្ឋ ឬឯកជនឡើយ ដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងប្រកាសនេះ រួមមាន ៖

- ឧបសម្ព័ន្ធ I ចែងអំពីការកំណត់រូបភាព និងលក្ខណៈសម្គាល់លតាបត្របង់ពន្ធ
- ឧបសម្ព័ន្ធ II ឧបសម្ព័ន្ធ III និងឧបសម្ព័ន្ធ IV ចែងអំពីការកំណត់ប្រាក់ពន្ធដែលត្រូវបង់តាមប្រភេទមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ។

**ប្រការ ៥.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបានលើកលែងចំពោះ ÷

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គិភ័យជាកម្មសិទ្ធិរបស់រដ្ឋ
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ជាកម្មសិទ្ធិរបស់អង្គភាព កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបម្រើការងារសម្រាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ជាកម្មសិទ្ធិរបស់ស្ថានទូត ឬស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

ស្ថាប័ន ឬអង្គភាពដែលជាម្ចាស់កម្មសិទ្ធិនៃមធ្យោបាយដឹកជញ្ជូន និងយានជំនិះ ដូចមានចែងក្នុងប្រការនេះ ត្រូវស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារដើម្បីទទួលបាននូវលតាបត្រលើកលែងពន្ធ ដោយភ្ជាប់មកជាមួយនូវបញ្ជីសារពើភណ្ឌរបស់ស្ថាប័ន ឬអង្គភាពដែលបានស្នើសុំនោះ ។

**ប្រការ ៦.-** ក្រោយពេលបង់ពន្ធរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ត្រូវទទួលបានលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធមួយសន្លឹក/បង្កាន់ដៃបង់ពន្ធមួយសន្លឹក និងលតាបត្រសម្រាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះមួយសន្លឹក ។ លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ/បង្កាន់ដៃបង់ពន្ធនេះត្រូវថែរក្សាទុកជាប់នឹងយានយន្ត សម្រាប់បង្ហាញមន្ត្រីមានសមត្ថកិច្ច និងជាឯកសារសម្រាប់ប្រកាសបង់ពន្ធនៅឆ្នាំបន្ទាប់ ។

**ប្រការ ៧.-** សម្រាប់ឆ្នាំ២០១៤ លតាបត្របង់ពន្ធដែលត្រូវបិទភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ មានរូបភាព និងលក្ខណៈសម្គាល់ ដូចមានចែងក្នុងឧបសម្ព័ន្ធ I ភ្ជាប់ជាមួយប្រកាសនេះ ។

**ប្រការ ៨.-** រថយន្តដឹកទំនិញធុនតូចដែលមានទ្វារ៤ (PICK UP) ÷

- ចាត់ទុកជារថយន្តទេសចរណ៍ ចំពោះរថយន្តមានអាយុកាលគិតពីឆ្នាំផលិតដល់ ០៧ឆ្នាំ នឹងត្រូវបង់ពន្ធតាមទំហំស៊ីឡាំង ដូចមានចែងក្នុងឧបសម្ព័ន្ធ III ភ្ជាប់ជាមួយនឹងប្រកាសនេះ
- ចាត់ទុកជារថយន្តដឹកទំនិញធុនតូច ចំពោះរថយន្តមានអាយុកាលគិតពីឆ្នាំផលិតលើសពី ០៧ឆ្នាំ នឹងត្រូវបង់ពន្ធតាមទម្ងន់ផ្ទុក ដូចមានចែងក្នុងឧបសម្ព័ន្ធ II ។

ចំពោះយានយន្តកែច្នៃផ្សេងទៀត ត្រូវចាត់ទុកជារថយន្តដឹកទំនិញ និងរ៉ឺម៉កសណ្តោង ដែលត្រូវកំណត់ដោយផ្អែកតាមទម្ងន់សរុប រួមមាន ទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញ-មនុស្ស) ដូចមានចែងក្នុងឧបសម្ព័ន្ធ IV ។

**ប្រការ ៩.-** មធ្យោបាយដឹកជញ្ជូន និងយានជំនិះទាំងឡាយណា ដែលមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់បណ្តាឆ្នាំមុនៗ ត្រូវបានលើកលែងពន្ធ និងប្រាក់ពិន័យសម្រាប់ឆ្នាំសារពើពន្ធដែលមិនបានបង់កន្លងមក ។ ប៉ុន្តែម្ចាស់យានយន្តទាំងនោះ ត្រូវមានកាតព្វកិច្ចបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ គិតចាប់ពីឆ្នាំ២០១៤ តទៅ ។

**ប្រការ ១០.-** ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ តទៅ អង្គភាពពន្ធដារត្រូវធ្វើការត្រួតពិនិត្យឲ្យបង់ពន្ធ និងជាកពិន័យ ចំពោះមធ្យោបាយដឹកជញ្ជូននិងយានជំនិះទាំងឡាយណាដែលមិនទាន់បានប្រកាសបង់ពន្ធ ។

**ប្រការ ១១.-** នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកនៃអគ្គនាយកដ្ឋាននានា ចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៤

អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អង្គភាពក្រោមឱវាទកសហវ “ដើម្បីអនុវត្ត”
- គ្រប់សាលារាជធានី-ខេត្ត “ដើម្បីសហការអនុវត្ត”
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...................សហវ

**ឧបសម្ព័ន្ធ I**
**ស្តីពី**
**ការកំណត់រូបភាព និងលក្ខណៈសម្គាល់បណ្ណបង់ពន្ធ**

ភ្ជាប់ជាមួយប្រកាសលេខ......សហវ.ប្រក ចុះថ្ងៃទី.....ខែ.....ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ក. ការកំណត់រូបភាព និងលក្ខណៈសម្គាល់**

បណ្ណបង់ពន្ធដែលត្រូវបិទភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១៤ មានរូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម ÷

**១.បណ្ណរាងរង្វង់មូល ÷**

**- ផ្ទៃខាងមុខ ÷**

+ ផ្ទៃកខាងលើនៃបណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" "**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**" "**ពន្ធដារ**" និងលេខ "2014"

+ ផ្ទៃកកណ្តាលនៃបណ្ណមានរូបហង្ស ពណ៌ទឹកមាសប្រាំពីរពណ៌ និងអក្សរ "**បណ្ណបង់ពន្ធត្រាក់ទ័រ**" ឬ "**បណ្ណបង់ពន្ធរថយន្ត**"

+ ផ្ទៃកខាងក្រោមនៃបណ្ណមានកម្រងស្លឹកឈើតាមរចនាបថអង្គរ ដោយអមជាមួយនូវលេខតំណាងទឹកប្រាក់ពន្ធ លេខរៀង ៧ខ្ទង់ និង Barcode។

**- ផ្ទៃខាងក្រោយ ÷** មានបង្កប់បន្ទះឈីប (Chip)។

❖ **បណ្ណរាងរង្វង់មូល មាន ១៧ពណ៌ និងតម្លៃ ដូចខាងក្រោម ÷**

**ក. សម្រាប់ត្រាក់ទ័រ ÷**

- បណ្ណពណ៌ស្វាទុំតម្លៃ ៣០.០០០រៀល មានកម្លាំងដល់ ៣៥សេះ
- បណ្ណពណ៌ផ្កាឈូកតម្លៃ ៤០.០០០រៀល មានកម្លាំងលើសពី ៣៥សេះ ដល់ ៦៥សេះ
- បណ្ណពណ៌លឿងខ្ចីតម្លៃ ៥០.០០០រៀល មានកម្លាំងលើសពី ៦៥សេះ ដល់ ៨២សេះ

**ខ. សម្រាប់រថយន្ត ÷**

- បណ្ណពណ៌ត្រួយចេកតម្លៃ ៨០.០០០រៀល ប្រើសម្រាប់រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១ ៥០០ ស.ម³ គិតពីឆ្នាំផលិតលើសពី ១០ឆ្នាំ
- បណ្ណពណ៌ក្រហមតម្លៃ ១០០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១ ៥០០ស.ម³ គិតពីឆ្នាំផលិតលើស ពី៥ឆ្នាំដល់១០ឆ្នាំ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

+ រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ១ ៥០០ស.ម³ ដល់ ២ ០០០ស.ម³ គិតពីឆ្នាំផលិតលើសពី ១០ឆ្នាំ

- បណ្ណពណ៌ផ្ទៃមេឃតម្លៃ ១៥០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១ ៥០០ស.ម³ គិតពីឆ្នាំផលិតដល់៥ឆ្នាំ
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ១ ៥០០ស.ម³ ដល់ ២ ០០០ស.ម³ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ ដល់១០ឆ្នាំ
  + រថយន្តដឹកទំនិញដល់៣តោន
  + រថយន្តដឹកអ្នកដំណើរមានកៅអី ដល់១៥កៅអី

- បណ្ណពណ៌ឈាមជ្រូកតម្លៃ ២០០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ១ ៥០០ស.ម³ ដល់ ២ ០០០ស.ម³ គិតពីឆ្នាំផលិតដល់៥ឆ្នាំ
  + រថយន្តដឹកអ្នកដំណើរធុនមធ្យមមានកៅអីពី១៦ ដល់២៥កៅអី

- បណ្ណពណ៌បៃតងចាស់តម្លៃ ២៥០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ស.ម³ គិតពីឆ្នាំផលិតលើសពី ១០ឆ្នាំ
  + រថយន្តដឹកអ្នកដំណើរធុនធំមានកៅអីលើសពី ២៥កៅអី
  + រថយន្តដឹកទំនិញលើសពី ៣តោន ដល់១០តោន
  + រ៉ឺម៉កសណ្តោងដល់១០តោន

- បណ្ណពណ៌ស្វាយតម្លៃ ៤០០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ស.ម³ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ ដល់១០ឆ្នាំ

- បណ្ណពណ៌ទឹកប៊ិចតម្លៃ ៤៥០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តដឹកទំនិញលើសពី ១០តោន ដល់២០តោន
  + រ៉ឺម៉កសណ្តោងលើសពី ១០តោន ដល់២០តោន

- បណ្ណពណ៌ឈាមជ្រូកហ៊ុំព័ទ្ធដោយពណ៌ផ្ទៃមេឃតម្លៃ ៦០០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ស.ម³ គិតពីឆ្នាំផលិតដល់៥ឆ្នាំ
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២ ៩០០ស.ម³ ដល់ ៤ ០០០ស.ម³ គិតពីឆ្នាំផលិតលើសពី ១០ឆ្នាំ

- បណ្ណពណ៌ស្វាយហ៊ុំព័ទ្ធដោយពណ៌ឈាមជ្រូកតម្លៃ ៧៥០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តដឹកទំនិញលើសពី ២០តោន
  + រ៉ឺម៉កសណ្តោងលើសពី ២០តោន

- បណ្ណពណ៌ផ្ទៃមេឃហ៊ុំព័ទ្ធដោយពណ៌លឿងខ្ចីតម្លៃ ៨០០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ៤ ០០០ស.ម$^{៣}$ គិតពីឆ្នាំផលិតលើសពី ១០ឆ្នាំ
- បណ្ណពណ៌ផ្ទៃមេឃហ៊ុំព័ទ្ធដោយពណ៌ក្រហមតម្លៃ ១.០០០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២ ៩០០ស.ម$^{៣}$ ដល់ ៤ ០០០ស.ម$^{៣}$ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ ដល់១០ឆ្នាំ
- បណ្ណពណ៌ត្រួយចេកហ៊ុំព័ទ្ធដោយពណ៌ស្វាយតម្លៃ ១.២០០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ៤ ០០០ស.ម$^{៣}$ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំដល់១០ឆ្នាំ
- បណ្ណពណ៌លឿងខ្ចីហ៊ុំព័ទ្ធដោយពណ៌ត្រួយចេកតម្លៃ ១.៦០០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២ ៩០០ស.ម$^{៣}$ ដល់ ៤ ០០០ស.ម$^{៣}$ គិតពីឆ្នាំផលិតដល់៥ឆ្នាំ
- បណ្ណពណ៌ផ្កាឈូកហ៊ុំព័ទ្ធដោយពណ៌ទឹកប៊ិចតម្លៃ ២.០០០.០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ៤ ០០០ស.ម$^{៣}$ ឡើងទៅ គិតពីឆ្នាំផលិតដល់៥ឆ្នាំ

**២. បណ្ណរាងពងក្រពើ ÷**

- ផ្នែកខាងលើនៃបណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" "**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**" "**ពន្ធដារ**" និងលេខ "2014"
- ផ្នែកកណ្តាលនៃបណ្ណមានរូបហង្ស ពណ៌ទឹកមាសប្រាំពីរពណ៌ និងអក្សរ "**បណ្ណបង់ពន្ធលើរថយន្ត**"
- ផ្នែកខាងក្រោមនៃបណ្ណមានកម្រងស្លឹកឈើតាមរចនាបថអង្គរ ដោយអមជាមួយនូវលេខតំណាងទឹកប្រាក់ពន្ធ លេខរៀង ៧ខ្ទង់ និងBarcode។

❖ **បណ្ណរាងពងក្រពើ មាន ៤ពណ៌ និងតម្លៃ ដូចខាងក្រោម ÷**

- បណ្ណពណ៌ទឹកប៊ិចតម្លៃ ៣.០០០រៀល ប្រើសម្រាប់ទោចក្រយានយន្តទំហំពិស្តុងដល់៧០សម$^{៣}$
- បណ្ណពណ៌លឿងខ្ចីតម្លៃ ៤.៥០០រៀល ប្រើសម្រាប់ទោចក្រយានយន្តមានទំហំពិស្តុងលើសពី៧០សម$^{៣}$ ដល់១២៥សម$^{៣}$
- បណ្ណពណ៌ស្លាទុំតម្លៃ ៧.៥០០រៀល ប្រើសម្រាប់ទោចក្រយានយន្តមានទំហំពិស្តុងលើសពី១២៥សម$^{៣}$ ឡើងទៅ
- បណ្ណពណ៌ផ្ទៃមេឃតម្លៃ ១៥.០០០រៀល ប្រើសម្រាប់ត្រីចក្រយានយន្ត (រំពាក់ដោយម៉ាស៊ីនម៉ូតូ) និងម៉ូតូរ៉ឺម៉កសណ្តោង។

**៣. បណ្ណរាងចតុកោណកែង ÷**

- ផ្នែកខាងលើនៃបណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" "**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**" "**ពន្ធដារ**" និងលេខ "2014"
- ផ្នែកកណ្តាលនៃបណ្ណមានរូបហង្ស ពណ៌ទឹកមាសប្រាំពីរពណ៌ និងអក្សរ "**បណ្ណបង់ពន្ធជលយាន**"
- ផ្នែកខាងក្រោមនៃបណ្ណមានកម្រងស្លឹកឈើតាមរចនាបថអង្គរ ដោយអមជាមួយនូវលេខរៀង ៧ខ្ទង់ និង Barcode។

- **បណ្ណរាងចតុកោណកែងមាន ៣ពណ៌ ត្រូវបង់ពន្ធតាមការកំណត់ដូចខាងក្រោម ÷**
  - បណ្ណពណ៌បៃតងប្រើសម្រាប់ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០.០០០រៀល ដល់៧០.០០០រៀល
  - បណ្ណពណ៌លឿងខ្ចីប្រើសម្រាប់ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០០.០០០ រៀល ដល់៥០០.០០០រៀល
  - បណ្ណពណ៌ក្រហមប្រើសម្រាប់ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ៦០០.០០០រៀល ដល់១.២០០.០០០រៀល។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ  សាសនា  ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច  និង  ហិរញ្ញវត្ថុ

លេខ...................សហវ

ឧបសម្ព័ន្ធ II

ស្តីពី

ការកំណត់ថ្លៃប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
ក្រៅពីរថយន្តទេសចរណ៍

ភ្ជាប់ជាមួយប្រកាសលេខ[illegible]សហវ.ប្រក ចុះថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឯកតា÷ រៀល

| ប្រភេទមធ្យោបាយដឹកជញ្ជូន និងយានជំនិះ | កម្រិតប្រាក់ពន្ធ សម្រាប់១ឆ្នាំ/គ្រឿង |
|---|---|
| **រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញ និងមនុស្ស)] ÷** | |
| - ដល់ ៣តោន | 150 000 |
| - លើសពី ៣តោន ដល់ ១០តោន | 250 000 |
| - លើសពី ១០តោន ដល់ ២០តោន | 450 000 |
| - លើសពី ២០តោន | 750 000 |
| **រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (ទម្ងន់រ៉ឺម៉ក និងទម្ងន់ផ្ទុក) ÷** | |
| - ដល់ ១០តោន | 250 000 |
| - លើសពី ១០តោន ដល់ ២០តោន | 450 000 |
| - លើសពី ២០តោន | 750 000 |
| **រថយន្តដឹកអ្នកដំណើរ ÷** | |
| - រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី | 150 000 |
| - រថយន្តដឹកអ្នកដំណើរធុនមធ្យម មានកៅអីពី ១៦កៅអី ដល់ ២៥កៅអី | 200 000 |
| - រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអីលើសពី ២៥កៅអី | 250 000 |
| **ត្រាក់ទ័រ និងគ្រឿងចក្រប្រហាក់ប្រហែល ÷** | |
| - ត្រាក់ទ័រកម្លាំងដល់ ៣៥សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | 30 000 |
| - ត្រាក់ទ័រកម្លាំងលើសពី ៣៥សេះ ដល់៦៥សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | 40 000 |
| - ត្រាក់ទ័រកម្លាំងលើសពី ៦៥សេះ ដល់៨២សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | 50 000 |

| | |
|---|---|
| **ទោចក្រយានយន្ត និងត្រីចក្រយានយន្ត** | |
| - ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ស.ម³ | 3 000 |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ៧០ស.ម³ ដល់ ១២៥ស.ម³ | 4 500 |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ១២៥ស.ម³ ឡើងទៅ | 7 500 |
| - ត្រីចក្រយានយន្តដឹកទំនិញ ឬអ្នកដំណើរ | 15 000 |
| **ជលយាន ឬជលយានយន្ត ផ្លូវទន្លេ÷** | |
| **- ជលយាន ឬជលយានយន្តដឹកទំនិញ÷** | |
| + ដល់ ៣តោន | 50 000 |
| + លើសពី ៣តោន ដល់ ១០តោន | 100 000 |
| + លើសពី ១០តោន ដល់ ២០តោន | 200 000 |
| + លើសពី ២០តោន | 300 000 |
| **- ជលយាន ឬជលយានយន្តដឹកអ្នកដំណើរ÷** | |
| + កប៉ាល់មានបណ្តោយដល់ ២០ ម៉ែត្រ | 100 000 |
| + កប៉ាល់មានបណ្តោយលើសពី ២០ម៉ែត្រ ដល់ ៣០ម៉ែត្រ | 200 000 |
| + កប៉ាល់មានបណ្តោយលើសពី ៣០ម៉ែត្រ ឡើងទៅ | 300 000 |
| **- ជលយាន ឬជលយានយន្តសណ្តោង÷** | |
| + កប៉ាល់មានកម្លាំងដល់ ៥០សេះ | 20 000 |
| + កប៉ាល់មានកម្លាំងលើសពី ៥០សេះ ដល់ ១០០សេះ | 30 000 |
| + កប៉ាល់មានកម្លាំងលើសពី ១០០សេះ ដល់ ១៥០សេះ | 50 000 |
| + កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | 60 000 |
| + កប៉ាល់មានកម្លាំងលើសពី ២០០សេះ ដល់ ២៥០សេះ | 180 000 |
| + កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ឡើងទៅ | 300 000 |
| **- ជលយាន ឬជលយានយន្តនេសាទ÷** | |
| + ទូកម៉ាស៊ីនចំហៀង " ជើងបង្គង " | 10 000 |
| + កាណូតមានកម្លាំងដល់ ៥០សេះ | 10 000 |
| + កាណូតមានកម្លាំងលើសពី ៥០សេះ ដល់ ១០០សេះ | 20 000 |
| + កាណូតមានកម្លាំងលើសពី ១០០សេះ ដល់ ១៥០សេះ | 30 000 |
| **ជលយាន ឬជលយានយន្ត ផ្លូវសមុទ្រ÷** | |
| **- ជលយាន ឬជលយានយន្តដឹកអ្នកដំណើរ ÷** | |
| + ទូកមានបណ្តោយដល់ ២០ម៉ែត្រ | 100 000 |
| + ទូកមានបណ្តោយពី ២១ម៉ែត្រ ដល់ ៣០ម៉ែត្រ | 150 000 |
| **- ជលយាន ឬជលយានយន្តដឹកទំនិញ ÷** | |
| + ទូកផ្ទុកទំនិញដល់ ១០០តោន | 200 000 |
| + កប៉ាល់ផ្ទុកទំនិញលើសពី ១០០តោន ដល់១ ០០០តោន | 300 000 |

| | |
|---|---|
| + កប៉ាល់ផ្ទុកទំនិញលើសពី ១ ០០០តោន ដល់ ២ ០០០តោន | 750 000 |
| + កប៉ាល់ផ្ទុកទំនិញលើសពី ២ ០០០តោន ឡើងទៅ | 1 200 000 |
| - ជលយាន ឬជលយានយន្តនេសាទ ÷ | |
| + ទូកម៉ាស៊ីនចំហៀង (ជើងបង្កង) ដល់ ១២សេះ | 10 000 |
| + ទូកម៉ាស៊ីនចំហៀង (ជើងបង្កង)លើសពី ១២សេះ ដល់ ៥០សេះ | 20 000 |
| + ទូកម៉ាស៊ីនចំហៀង (ជើងបង្កង) លើសពី ៥០សេះ ឡើងទៅ | 50 000 |
| + ទូកមានកម្លាំងដល់ ៩សេះ | 10 000 |
| + ទូកមានកម្លាំងពី ១០សេះ ដល់ ២០សេះ | 15 000 |
| + ទូកមានកម្លាំងលើសពី ២០សេះ ដល់ ៤០សេះ | 25 000 |
| + ទូកមានកម្លាំងលើសពី ៤០សេះ ដល់ ៨០សេះ | 50 000 |
| + ទូកមានកម្លាំងលើសពី ៨០សេះ ដល់ ១៥០សេះ | 70 000 |
| + ទូកមានកម្លាំងលើសពី ១៥០សេះ ឡើងទៅ | 100 000 |
| + កប៉ាល់មានកម្លាំងដល់ ១៥០សេះ | 300 000 |
| + កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២៥០សេះ | 400 000 |
| + កប៉ាល់កម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | 600 000 |
| + កប៉ាល់មានកម្លាំងលើសពី ៥០០សេះ ឡើងទៅ | 1 200 000 |
| - ជលយាន ឬជលយានយន្តសណ្តោង ÷ | |
| + កប៉ាល់មានកម្លាំងដល់ ២៥០សេះ | 200 000 |
| + កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | 400 000 |
| + កប៉ាល់មានកម្លាំងលើសពី ៥០០សេះ ឡើងទៅ | 600 000 |
| **អ្នកបើកបរផ្លូវទន្លេ/សមុទ្រ ÷** | |
| - មានកម្លាំងដល់ ២៥សេះ | 150 000 |
| - មានកម្លាំងលើសពី ២៥សេះ ដល់ ៤០សេះ | 200 000 |
| - មានកម្លាំងលើសពី ៤០សេះ ដល់ ៨០សេះ | 300 000 |
| - មានកម្លាំងលើសពី ៨០សេះ ដល់ ២០០សេះ | 400 000 |
| - មានកម្លាំងលើសពី ២០០សេះ ឡើងទៅ | 500 000 |

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ....................សហវ

## ឧបសម្ព័ន្ធ III

ស្តីពី

## ការកំណត់ប្រាក់ពន្ធតាមទំហំស៊ីឡាំងរបស់រថយន្តទេសចរណ៍

ភ្ជាប់ជាមួយប្រកាសលេខ.៥៤៨.ប្រក. សហវ. អពដ ចុះថ្ងៃទី.០៧. ខែ.ឧសភា. ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឯកតា ÷ រៀល

| ល.រ | ទំហំស៊ីឡាំងគិតជា សម$^{៣}$ "CC" | គិតពីឆ្នាំផលិត | | |
|---|---|---|---|---|
| | | ដល់ ៥ឆ្នាំ | លើសពី៥ឆ្នាំ ដល់១០ឆ្នាំ | លើសពី ១០ឆ្នាំ |
| ១. | ដល់ ១ ៥០០ស.ម$^{៣}$ | ១៥០ ០០០ | ១០០ ០០០ | ៨០ ០០០ |
| ២. | លើសពី ១ ៥០០ស.ម$^{៣}$ ដល់ ២ ០០០ស.ម$^{៣}$ | ២០០ ០០០ | ១៥០ ០០០ | ១០០ ០០០ |
| ៣. | លើសពី ២ ០០០ស.ម$^{៣}$ ដល់ ២ ៩០០ស.ម$^{៣}$ | ៦០០ ០០០ | ៤០០ ០០០ | ២៥០ ០០០ |
| ៤. | លើសពី ២ ៩០០ស.ម$^{៣}$ ដល់ ៤ ០០០ស.ម$^{៣}$ | ១ ៦០០ ០០០ | ១ ០០០ ០០០ | ៦០០ ០០០ |
| ៥. | លើសពី ៤ ០០០ស.ម$^{៣}$ ឡើងទៅ | ២ ០០០ ០០០ | ១ ២០០ ០០០ | ៨០០ ០០០ |

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

លេខ....................សហវ

# ឧបសម្ព័ន្ធ IV
## ស្តីពី
## ការកំណត់ប្រាក់ពន្ធសម្រាប់រថយន្តដឹកទំនិញ និងរ៉ឺម៉កសណ្តោង
## ដែលកំណត់ដោយផ្អែកតាមទម្ងន់សរុប រួមមានទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញ-មនុស្ស)

ភ្ជាប់ជាមួយប្រកាសលេខ៥៤៩ ប្រក. សហវ. អពជ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឯកតា ÷ រៀល

| ល.រ | ប្រភេទ | ចំនួនប្រាក់ពន្ធ |
|---|---|---|
| ១ | រថយន្តដែលបំប្លែងមកពីគោយន្ត និងរថយន្តកៃច្នៃកង់បី (បំពាក់ដោយម៉ាស៊ីនរថយន្ត) ត្រូវកំណត់ជារថយន្តដឹកទំនិញដល់៣តោន | ១៥០.០០០ រៀល |
| ២ | រ៉ឺម៉កសណ្តោងដែលមានភ្លៅ២ កង់៤ | ២៥០.០០០ រៀល |
| ៣ | រ៉ឺម៉កសណ្តោងដែលមានភ្លៅ២ កង់៨ | ៤៥០.០០០ រៀល |
| ៤ | រថយន្តដឹកទំនិញដែលមានភ្លៅ៣ កង់៦ | ៤៥០.០០០ រៀល |
| ៥ | រថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ៣ កង់១០។ | ៧៥០.០០០រៀល |

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៤
រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អូន ព័ន្ធមុនីរ័ត្ន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ៥៥០ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើតមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តត្បូងឃ្មុំ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតខេត្តត្បូងឃ្មុំ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៩៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩១ សហវ.ប្រក. ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh. CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

## សម្រេច

**ប្រការ១.–**

ត្រូវបានបង្កើតមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តត្បូងឃ្មុំ ដែលត្រូវបំពេញមុខងារជាតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្នាក់មូលដ្ឋាន និងត្រូវស្ថិតនៅក្រោមការសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២.–**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តត្បូងឃ្មុំ ត្រូវអនុលោមទៅតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ... ឆ្នាំ២០១៤

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ